# ឯកសារស្រាវជ្រាវ

សមាជិកព្រឹទ្ធសភាក្រុមទី៦

## ស្តីពី
## ការគ្រប់គ្រងចំណូលពីឧស្ម័ន និងប្រេង

រៀបចំដោយៈ  សេប៉ាស្ទាន អ៉ាប់ចូវ៉ែនស៊ិន

រាជធានីភ្នំពេញ ខែសីហា ឆ្នាំ២០១៨

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា

**១- សេចក្តីផ្តើម**

**២- លក្ខខណ្ឌសារពើពន្ធ**

២.១ កិច្ចព្រមព្រៀងសម្បទាន និងកិច្ចព្រមព្រៀងចែករំលែកផលិតកម្ម
២.២ ការចាត់ចែងសួយសារ និងចំណូល
២.៣ ការធ្វើឲ្យមានតុល្យភាពរវាងសួយសាររដ្ឋ និងការទាក់ទាញវិនិយោគទុនលើការរុករក និងផលិតប្រេង និងឧស្ម័ន

**៣- ប្រព័ន្ធគ្រប់គ្រងចំណូលប្រេង និងឧស្ម័ន**

៣.១ ការចំណាយដែលកើនឡើងតាមចំណូលទទួលបានពីប្រេង និងឧស្ម័ន (Spend-as-you-go)
៣.២ ទ្រព្យក្នុងដៃ (Bird in hand)
៣.៣ សម្មតិកម្មចំណូលអចិន្ត្រៃយ៍ (PIH) (Permanent Income Hypothesis)
៣.៤ វិធីសាស្ត្របង្កើនការចំណាយជាបណ្តើរៗ (Gradual Scaling Approach)

**៤. ហានិភ័យផ្នែកនយោបាយ និងសេដ្ឋកិច្ច និងកាលានុវត្តភាព នៃចំណូលទ្រព្យធំដែលទទួលបានពីប្រេង និងឧស្ម័ន**

៤.១ ហានិយភ័យ
៤.២ ការបញ្ចៀសហានិយភ័យ
៤.៣ កាលានុវត្តភាព

**៥. ករណីសិក្សា**

៥.១ ប្រទេសម៉ិកស៊ីកូ
៥.២ ប្រទេសទីម័រខាងកើត

**៦. សេចក្តីសន្និដ្ឋាន**

## ១-	សេចក្តីផ្តើម

ក្នុងអត្រាមធ្យមនៃផលិតកម្ម ចំណូលពីប្រេង និងឧស្ម័នក្នុងប្រទេសកម្ពុជា ត្រូវបានប៉ាន់ស្មានថាមានតម្លៃប្រហែល ៥ រយលានដុល្លាអាមេរិកក្នុងមួយឆ្នាំ ក្នុងរយៈពេលពី ២០ ទៅ ២៥ ឆ្នាំ ហើយក៏មានការប៉ាន់ស្មានថានឹងកើនឡើងខ្ពស់បំផុតក្នុងចន្លោះ ១.៧ ពាន់លានដុល្លាសហរដ្ឋអាមេរិក ដល់ ៦ ពាន់លានដុល្លាសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំៗ ក្នុងអំឡុងពេលមិនច្រើនឆ្នាំប៉ុន្មានឡើយ[1]។ ប៉ុន្តែការធ្លាក់ចុះតម្លៃប្រេង និងឧស្ម័នពេលកន្លងទៅថ្មីៗនេះ ដែលត្រូវបានព្យាករណ៍ថានឹងបន្តធ្លាក់ចុះនាពេលអនាគតខាងមុខ មូលហេតុចំបងដោយសារមានគម្រោងរុករកឧស្ម័នធំៗ កំពុងបានចាប់ផ្តើមដំណើរការផលិតកម្មរបស់ខ្លួននៅទូទាំងពិភពលោកនោះ[2] ការចាប់អារម្មណ៍ និងផលចំណេញ ក្នុងការអភិវឌ្ឍវិស័យប្រេង និងឧស្ម័នបម្រុងនៅកម្ពុជា អាចថយចុះ។ មូលហេតុនេះ អាចជាកត្តាជម្រុញឲ្យក្រុមហ៊ុន Chevron លក់សិទ្ធិផលិតកម្មរបស់ខ្លួន ដោយខាតបង់ទឹកប្រាក់ប្រហែល១០០លានដុល្លាអាមេរិក[3]។ អាជ្ញាប័ណ្ណសម្រាប់ការរុករក និង ផលិតប្រេង និងឧស្ម័នរបស់ប្រទេសកម្ពុជា ត្រូវបានបែងចែកជាប្លុក ដូចបានបង្ហាញក្នុងរូបភាពទី១ ខាងក្រោម ។ មកទល់នឹងពេលបច្ចុប្បន្ន ការងាររុករក ក្នុងប្លុក ក គឺមានសកម្មភាពច្រើន ខណៈពេលដែលអធិបតេយ្យភាពនៃប្លុកមួយចំនួនដែលហៅថាជាតំបន់ត្រួតស៊ីគ្នា (OCA) នោះ មិនទាន់ត្រូវបានប្រទេសកម្ពុជា និងប្រទេសថៃដោះស្រាយឲ្យបានដាច់ស្រេចនៅឡើយទេ[4]។

[1]IMF, *Cambodia: Selected Issues and Statistical Appendix*, Country Report (Washington DC: IMF, 2007), http://www.imf.org/external/pubs/ft/scr/2007/cr07291.pdf; UNDP, *Review of Development Prospects and Options For the Cambodian Oil and Gas Sector*, Discussion Paper, Insights for Action (Phnom Penh: UNDP Cambodia, 2006).

[2]"Shell's Massive Prelude Hull World's Biggest-Ever Floating Vessel and First Ocean-Based LNG Plant," *Financial Post*, accessed August 15, 2014, http://business.financialpost.com/2013/12/03/record-breaking-lng-ship-launched-bigger-one-planned/; "Chevron To Sell Shares of Cambodian Offshore Oil and Gas," *VOA*, accessed August 15, 2014, http://www.voacambodia.com/content/chevron-to-sell-shares-of-cambodian-offshore-oil-and-gas/2413411.html.

[3]"Chevron To Sell Shares of Cambodian Offshore Oil and Gas."

[4]"Oil and Gas Blocks | Open Development Cambodia," accessed August 18, 2014, http://www.opendevelopmentcambodia.net/briefing/oil-and-gas-blocks/.




**រូបទី ១៖ ប្លុកប្រេង និងឧស្ម័ន និងតំបន់ត្រួតស៊ីគ្នា (OCA) ដែលប្រទេសកម្ពុជា និងប្រទេសថៃទាមទារកាន់កាប់ក្នុងពេលជាមួយគ្នា**[5]

របាយការណ៍មួយរបស់កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UNDP) កត់សម្គាល់ថា ការប៉ាន់ស្មានប្រេង និងឧស្ម័នបម្រុងនៅកម្ពុជា ជាទូទៅមិនមានភស្តុតាងបញ្ជាក់ច្បាស់លាស់ឡើយ ហើយទន្ទឹមនឹងនោះ របាយការណ៍ក៏បានកត់សម្គាល់ដោយប្រុងប្រយ័ត្នចំពោះគោលនយោបាយសេដ្ឋកិច្ចមួយចំនួន។ របាយការណ៍នោះ លើកឡើងថាការអភិវឌ្ឍស្ថាប័នកម្ពុជា ដូចជាអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាកត្តាដ៏សំខាន់បំផុតក្នុងការកំណត់ថាតើប្រទេសកម្ពុជាទទួលបានផលចំណេញច្រើនប៉ុណ្ណាពីសក្តានុពលនៃធនធានប្រេង និងឧស្ម័ន របស់ខ្លួន[6]។ របាយការណ៍នេះ បង្ហាញនូវបញ្ហាប្រឈមជាច្រើនចំពោះប្រទេសកម្ពុជា ដោយសារជាទូទៅមាន ឯកសារជាច្រើនអះអាងថា ប្រភពធនធានធម្មជាតិ ដូចជាប្រេង និងឧស្ម័ននៅក្នុងវិស័យសេដ្ឋកិច្ច តែងតែមានផលប៉ះពាល់អវិជ្ជមានលើការអភិវឌ្ឍសេដ្ឋកិច្ច[7] គុណភាពនៃអភិបាលកិច្ច[8] និងស្ថេរភាពនយោបាយ[9]។ ជាពិសេសករណីទាំងនេះច្រើនកើតឡើងក្នុងប្រទេសដែលមិនទាន់មានស្ថាប័នរឹងមាំ ហើយដែលងាយស្រួលនឹង

---

[5] ដូចជើងទំព័រខាងលើ

[6] UNDP, *Review of Development Prospects and Options For the Cambodian Oil and Gas Sector.*

[7] Jeffrey Frankel A, *The Natural Resources Curse: A Survey of Diagnoses and Some Prescriptions*, Working Paper, Faculty Research Working Paper Series (Cambridge, MA: Harvard University, Kennedy School of Government, 2012).p. 2.

[8] World Bank, *Oil and Gas: A Blessing or a Curse?*, Cambodia Oil & Gas Briefing Notes (Washington DC: World Bank, 2007), http://siteresources.worldbank.org/INTOGMC/Resources/cambodia_oil_gas_newsletter_2.pdf; The Economist, "The Curse of Oil: The Paradox of Plenty," *The Economist*, December 20, 2005, 20/12/2005 edition, http://www.economist.com/node/5323394.p. 2.

[9] The Economist, "The Curse of Oil."

កើតអំពើពុករលួយ[10]។ ជាញឹកញាប់ ស្ថានភាពបែបនេះត្រូវបានចាត់ទុកថាជា "បណ្តាសាធនធាន" ដែលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ អ្នកជំនាញសេដ្ឋកិច្ចជាច្រើន បានឯកភាព និងមានការបញ្ជាក់អះអាងពីការសិក្សាស្រាវ ជ្រាវដែលមានការទទួលស្គាល់ច្រើន[11]។ តាមរយៈការស្រាវជ្រាវបច្ចុប្បន្ននេះ ដើម្បីជៀសវាងបណ្តាសាធនធានបែបនេះ ចាំបាច់បំផុត ប្រទេសកម្ពុជា ត្រូវរៀបចំបង្កើតកិច្ចសន្យាឲ្យបានសមស្របជាមួយក្រុមហ៊ុនរុករកប្រេង និងឧស្ម័ន និងស្ថាប័នសំខាន់ៗនានា ដើម្បីគ្រប់គ្រងចំណូលដែលទទួលបានពីប្រេង និងឧស្ម័ន ឲ្យបានជោគជ័យ។

ឯកសារស្រាវជ្រាវនេះ នឹងពិនិត្យមើលកត្តានានា ដែលមានភាពទាក់ទងបំផុតទៅនឹងប្រទេសមួយដែលទទួលផលចំណេញពីចំណូលប្រេង និងឧស្ម័នរបស់ខ្លួន ដែលបែងចែកជាបួនផ្នែក គឺស្តីពីលក្ខខណ្ឌសារពើពន្ធនៃកិច្ចសន្យាស្តីពីផលិតកម្ម, ការគ្រប់គ្រងចំណូលពីប្រេង និងឧស្ម័នហានិយភ័យដែលពាក់ព័ន្ធ, ការបញ្ចៀសហានិយភ័យ និងកាលានុវត្តភាព។ ជាចុងក្រោយ ឯកសារស្រាវជ្រាវនេះ នឹងបង្ហាញពីករណីសិក្សានៃប្រទេសម៉ិកស៊ិក និងទីម័រខាងកើត ដោយហេតុថាករណីសិក្សាទាំងពីរនេះ អាចផ្តល់មេរៀនច្បាស់ៗស្តីពីហានិយភ័យ និងផលចំណេញ ដែលអាចទទួលបានពីចំណូលប្រេង និងឧស្ម័ន។ ផ្នែកទីមួយ នឹងពិនិត្យមើលភាពខុសគ្នារវាងកិច្ចសន្យាផលិតប្រេងផ្សេងៗ និងសារៈសំខាន់នៃការជ្រើសរើសដោយប្រុងប្រយ័ត្ននូវលក្ខខណ្ឌនានានៃកិច្ចសន្យា គឺក្នុងនោះរួមមានតុល្យភាពដ៏សមស្របរវាងការទាក់ទាញវិនិយោគទុនដែលត្រូវចំណាយទុនខ្ពស់សម្រាប់ការរុករក និងសារៈសំខាន់ក្នុងការធានាថារដ្ឋនឹងទទួលបានសួយសារខ្ពស់គ្រប់គ្រាន់ពីផលិតកម្មប្រេង និងឧស្ម័ន។ ផ្នែកទីពីរ នឹងធ្វើការប្រៀបធៀបប្រព័ន្ធមួយចំនួននៃការគ្រប់គ្រងចំណូលពីប្រេង និងឧស្ម័ន ដែលជាសំខាន់គឺសម្រាប់ឲ្យប្រទេសកំពុងអភិវឌ្ឍន៍ យកមកពិចារណា ដោយហេតុការចំណាយប្រាក់ច្រើនសន្ធឹកសន្ធាប់នៅដើមទី អាចបង្កឲ្យមានផលប៉ះពាល់យ៉ាងគ្រោះថ្នាក់ និងខ្ជះខ្ជាយធនធានជាតិខណៈដែលការចំណាចតិចតួចពេកនៅពេលចាប់ផ្តើម អាចអូសបន្លាយភាពក្រីក្រ និងកាត់បន្ថយការអភិវឌ្ឍសេដ្ឋកិច្ចនាពេលអនាគត។ ផ្នែកទីបី នឹងលាតត្រដាងពីហានិយភ័យធំៗ យុទ្ធសាស្ត្របញ្ចៀសហានិយភ័យ និងកាលានុវត្តភាព ដែលកើតចេញពីពីចំណូលសំខាន់ៗនៃប្រេង និងឧស្ម័ន។ ផ្នែកចុងក្រោយ នឹងសង្ខេបជូននូវករណីរសិក្សាអំពីប្រទេសម៉ិកស៊ិក និងទីម័រខាងកើត ដើម្បីបង្ហាញអំពីបញ្ហាមួយចំនួន ដែលបានលើកឡើងខាងលើ។

---

[10]Robert Deacon T and Bernardo Mueler, "Political Economy and Natural Resouce Use," in *Economic Development and Environmental Sustainability*, ed. Ramon Lopez and Michael Toman A (Oxford: Oxford University Press, 2006). p. 138
[11]Frankel, *The Natural Resources Curse*.

# ២. លក្ខខណ្ឌសារពើពន្ធ

## ២.១ កិច្ចព្រមព្រៀងសម្បទាន និងកិច្ចព្រមព្រៀងចែករំលែកផលិតកម្ម

មានឧទាហរណ៍ពីរស្តីពីកិច្ចព្រមព្រៀងរុករកប្រេង និងឧស្ម័នគឺៈ កិច្ចព្រមព្រៀងសម្បទាន និង កិច្ចព្រមព្រៀងចែករំលែកផលិតកម្ម (PSA)[12]។ កិច្ចព្រមព្រៀងសម្បទាន ជាសំខាន់គឺពាក់ព័ន្ធនឹងរដ្ឋ ជួលកន្លែងរុករកប្រេង ឬឧស្ម័នឲ្យទៅក្រុមហ៊ុនរុករក ដោយរដ្ឋទទួលបានសួយសារ ជាសាច់ប្រាក់[13]។ រីឯកិច្ចព្រមចែករំលែកផលិតកម្ម (PSA) ជាកិច្ចព្រមព្រៀង ដែលរដ្ឋទទួលបានចំណែកដែលបានកំណត់ទុក ដោយយោងទៅលើពីធនធានដែលរុករកបាន[14]។ ទោះជាយ៉ាងនេះក្តី ក្នុងចំណោមប្រព័ន្ធទាំងពីរ មិនមានប្រព័ន្ធមួយណា ប្រសើរជាងប្រព័ន្ធណាឡើយ។ លក្ខខណ្ឌជាក់លាក់នៃកិច្ចសន្យា តម្លៃប្រេង និងឧស្ម័ននាពេលអនាគត ព្រមទាំងបរិមាណប្រេង និងឧស្ម័នដែលអាចរុករកបានក្នុងតម្លៃដើមទាបសមរម្យ ជាកត្តាកំណត់នៃផលចំណេញ ដែលកិច្ចព្រមព្រៀងទាំងនេះ នឹងផ្តល់ឲ្យដល់ភាគីនីមួយៗ ជាជាងការកំណត់ជាលក្ខខណ្ឌរួមនៅក្នុងកិច្ចព្រមព្រៀង[15]។ ជាការពិត ធនាគារពិភពលោក អះអាងថាការជ្រើសរើសរបស់រដ្ឋាភិបាលនូវទម្រង់ណាមួយនៃកិច្ចព្រមព្រៀងជាការសម្រេចចិត្តផ្នែកនយោបាយសុទ្ធសាធ។ យោងតាមធនាគារពិភពលោក កិច្ចព្រមព្រៀងចែករំលែកផលិតកម្ម (PSA) ត្រូវបានមើលឃើញថាអនុញ្ញាតឲ្យរដ្ឋគ្រប់គ្រងបានណែនជាង និងរក្សាបានភាពជាម្ចាស់លើធនធានធម្មជាតិរបស់ខ្លួន ជាជាងកិច្ចព្រមព្រៀងសម្បទានដែលជាការលក់សិទ្ធិបែបនេះទាំងស្រុងដល់ក្រុមហ៊ុនរុករក[16]។

## ២.២ ប្រព័ន្ធគ្រប់គ្រងសួយសារ និងចំណូល

មានយន្តការផ្សេងៗគ្នាមួយចំនួន អាចប្រើប្រាស់ជាប្រព័ន្ធគ្រប់គ្រងចំណូលដែលរដ្ឋនឹងទទួលបានពីគម្រោងមួយ ហើយថាតើចំណូលនោះមានការប្រែប្រួលបែបណាទៅតាមពេលវេលា។ កិច្ចសន្យាទាំងនេះ អាចផ្តល់ចំណូលជាសាច់ប្រាក់ ឬជាប្រេង ឬឧស្ម័ន ទោះជាជ្រើសរើសយក តាមប្រព័ន្ធមួយណាក៏ដោយ។ ជារឿយៗ កិច្ចព្រមព្រៀងចែករំលែកផលិតកម្ម (PSA) ត្រូវបានរៀបចំឡើង ដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុនរុករក ទទួលបានបរិមាណមួយចំនួននៃធនធានក្នុងរយៈពេល ដែលបានកំណត់ជាឆ្នាំ ដោយមិនផ្តល់ចំណែកណាមួយដល់រដ្ឋឡើយ ដើម្បីជាការទូទាត់លើការចំណាយ

---

[12]World Bank, *Contracts for Petroleum Development - Part 1*, Cambodia Oil & Gas Briefing Notes (Washington DC: World Bank, 2007), http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTOGMC/0,,contentMDK:21852379~menuPK:5242468~pagePK:210058~piPK:210062~theSitePK:336930,00.html#CambodiaO&GNotes.

[13]Royalties are a fee paid for the usage of something, which in this case would be oil or gas fields. http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTOGMC/0,,contentMDK:21852379~menuPK:5242468~pagePK:210058~piPK:210062~theSitePK:336930,00.html#CambodiaO&GNotes.

[14]World Bank, *Contracts for Petroleum Development - Part 1*.

[15] ដូចជើងទំព័រខាងលើ

[16] ដូចជើងទំព័រខាងលើ

វិនិយោគរបស់ខ្លួន។ ជាទូទៅ តាមកិច្ចព្រមព្រៀងសម្បទាន ក្រុមហ៊ុនរុករក នឹងបង់សួយសារចំនួនតិចតួចដល់រដ្ឋ រហូតដល់ផលិតបាន "បរិមាណប្រេងគិតជាតម្លៃ" ដែលបានកំណត់ជាមុនក្នុងការទូទាត់លើការចំណាយវិនិយោគទុនរបស់ខ្លួន។

| **ប្រេងក្នុងតម្លៃ១០០ដុល្លា** | | |
|---|---|---|
| **អ្នកម៉ៅការ** | **សួយសារ** | **រដ្ឋ** |
| | ១០% | $១០ |
| | **ប្រេងថ្លៃដើម** | |
| $២៥ | ៦០% | |
| | ការកំណត់តាមឆ្នាំនីមួយៗ | |
| | **ប្រាក់ចំណេញពីប្រេង** | |
| $២៦ | ៤០/៦០ | $៣៩ |
| | **ពន្ធ** | |
| -$៧.៨ | ៣០% | $៧.៨ |
| $៤៣.២ | **សរុប** | $៥៦.៨ |

តារាងទី១- ឧទាហរណ៍នៃការបែងចែកប្រាក់ចំណេញទទួលបានពីប្រេងក្នុងតម្លៃ១០០ដុល្លា[17]

តារាងទី១ខាងលើ ជាឧទាហរណ៍នៃលំហូរប្រាក់ចំណូល ផ្អែកលើក្រោមកិច្ចព្រមព្រៀងសម្បទាន [18]។

ខនានា ទាក់ទងដល់សិទ្ធទទួលសួយសារបន្ថែម[19] អាចនឹងដាក់បញ្ចូលបានក្នុងកិច្ចព្រមព្រៀង ដោយចែងថា ប្រសិនបើអាចបញ្ជាក់ថាមានរ៉ែធម្មជាតិច្រើនជាងការរំពឹងទុកដែលអាចរុករកបាន

[17]World Bank, *Contracts for Petroleum Development - Part 2*, Cambodia Oil & Gas Briefing Notes (Washington DC: World Bank, 2007), 2, http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTOGMC/0,,contentMDK:21852379~menuPK:5242468~pagePK:210058~piPK:210062~theSitePK:336930,00.html#CambodiaO&GNotes.
[18]World Bank, *Contracts for Petroleum Development - Part 2*.

ដោយនិរន្តរភាព ឬក៏មានកំណើនតម្លៃប្រេង ឬឧស្ម័នលើសពីកម្រិតណាមួយនោះ រដ្ឋមានសិទ្ធិទទួលបានសួយសារបន្ថែម។ ជារឿយៗ ចំណុចទាំងនេះ ត្រូវបានដាក់បញ្ចូលក្នុងកិច្ចព្រមព្រៀង ពីព្រោះបើតាមទស្សនទានរបស់ក្រុមហ៊ុនរុករក ចំណុចទាំងនេះមិនបង្កើតហានិយភ័យបន្ថែមចំពោះការវិនិយោគដែលមិនទទួលបានប្រាក់ចំណេញឡើយ ហើយខនៃកិច្ចព្រមព្រៀងនេះទាក់ទងដល់សិទ្ធទទួលសួយសារបន្ថែម ដែលអាចអនុវត្តបានលុះត្រាតែក្រុមហ៊ុនរុករក បានទូទាត់ការចំណាយ និងទទួលបានប្រាក់ចំណេញដល់កម្រិតដែលបានព្រមព្រៀងគ្នារួចមកហើយ។ រីឯតាមទស្សនរបស់រដ្ឋ ខនៃកិច្ចព្រមព្រៀងទាក់ទងដល់ដល់សិទ្ធទទួលសួយសារបន្ថែមនេះ ជាយន្តការដ៏សមស្រប ដើម្បីធានាថាសក្តានុពលនៃចំណូលនៃធនធានប្រេង និងឧស្ម័នត្រូវបានបង្កើនដល់កម្រិតអតិបរមា[20]។




មានវិធីសាស្ត្រដាច់ដោយឡែកពីគ្នាចំនួនពីរ សម្រាប់កិច្ចសន្យាប្រេង និងឧស្ម័នគឺៈ ប្រព័ន្ធដែលមានលក្ខណៈថយចុះ (Regressive) និងប្រព័ន្ធដែលមានលក្ខណៈកើនឡើង (Progressive) ។ ប្រព័ន្ធដែលគេដាក់ឈ្មោះថា មានលក្ខណៈថយចុះ គឺដោយសារសួយសាររបស់រដ្ឋ ត្រូវបានគណនាក្នុងអត្រាថេរក្នុងអំឡុងពេលនៃគម្រោងទាំងមូល។ ជាទូទៅ កិច្ចព្រមព្រៀងតាមប្រព័ន្ធដែលមានលក្ខណៈថយចុះ ផ្តល់ចំណូលខ្ពស់ដល់រដ្ឋនៅពេលចាប់ផ្តើម ប៉ុន្តែនោះមានន័យថាសួយសាររបស់ប្រទេសមួយ នឹងមិនកើនឡើងឡើយ ទោះបីជាប្រាក់ចំណេញកើនឡើងដោយសារតម្លៃប្រេងឡើងថ្លៃ ឬថ្លៃដើមផលិតកម្មថយចុះក៏ដោយ។ កត្តានេះ អាចប៉ះពាល់ដល់ចំណែកនៃប្រាក់ចំណេញសរុបរបស់រដ្ឋ ដែលថយចុះក្នុងអំឡុងពេលវេលាមួយ ទោះជាផលចំណេញ កើនឡើងក៏ដោយ[21]។

---

[19] ពាក្យថា "Windfalls" សំដៅទៅលើប្រាក់ចំណេញចំនួនច្រើនដោយមិនមានការរំពឹងទុក

[20] World Bank, *Contracts for Petroleum Development - Part 2*.

[21] World Bank, *Contracts for Petroleum Development - Part 3*, Cambodia Oil & Gas Briefing Notes (Washington DC: World Bank, 2008), http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTOGMC/0,,contentMDK:21852379~menuPK:5242468~pagePK:210058~piPK:210062~theSitePK:336930,00.html#CambodiaO&GNotes.

រូបទី២៖ ឧទាហរណ៍នៃការបែងចែកផលិតកម្មក្នុងរយៈពេលមួយ ដែលតម្លៃប្រេងកើនឡើង ក្រោមប្រព័ន្ធចែករំលែកផលិតកម្មដែលមានលក្ខណៈថយចុះ (ករណីទី១) និងប្រព័ន្ធចែករំលែកផលិតកម្មដែលមានលក្ខណៈកើនឡើង (ករណីទី២)[22]

ជាជម្រើស កិច្ចសន្យា អាចធ្វើឡើងតាមប្រព័ន្ធដែលមានលក្ខណៈកើនឡើង ដែលចំណែកនៃប្រាក់ចំណេញសរុបរបស់រដ្ឋ កើនឡើងស្របតាមការកើនឡើងនៃផលចំណេញ ដោយសារទទួលបានប្រេង ឬ ឧស្ម័នបម្រុង ក្នុងបរិមាណច្រើនជាងការរំពឹងទុក ឬតម្លៃប្រេង និងឧស្ម័នកើនឡើង។ ដូចបង្ហាញក្នុងរូបទី២ ក្រោមកិច្ចព្រមព្រៀងចែករំលែកផលិតកម្មដែលមានលក្ខណៈកើនឡើង គឺរដ្ឋទទួលបានសួយសារតិចជាង នៅពេលចាប់ផ្តើម។ ក៏ប៉ុន្តែ នៅក្នុងរយៈពេលបន្ទាប់នៃគម្រោង នៅពេលតម្លៃប្រេងកើនឡើង វិធីសាស្ត្រនេះ ផ្តល់សួយសារដល់រដ្ឋ ច្រើនជាងប្រព័ន្ធចែករំលែកផលិតកម្មតាមកិច្ចសន្យាដែលមានលក្ខណៈថយចុះ[23]។

## ២.៣ ការធ្វើឲ្យមានតុល្យភាពរវាងសួយសាររបស់រដ្ឋ និងការទាក់ទាញវិនិយោគទុនលើការរុករក និងផលិតកម្ម

ប្រសិនបើកំណត់ពន្ធ និងសួយសារ ក្នុងកម្រិតខ្ពស់ពេកនោះ ទីតាំងរ៉ែប្រេង និងឧស្ម័នដែលអាចទទួលប្រាក់ចំណេញទាប ទំនងជាមិនជាអាចធ្វើអាជីវកម្មបានឡើយ។ នោះបណ្តាលឲ្យរដ្ឋបាត់បង់សក្តានុពលចំណូល។ ប្រសិនបើកំណត់ថ្លៃដើមទាបពេក រដ្ឋក៏ខាតបង់សក្តានុពលចំណូលផងដែរ។ ដើម្បីកំណត់ពន្ធ ឬថ្លៃដើមឲ្យបានត្រឹមត្រូវ វាទាមទារធ្វើការប៉ាន់ស្មានដោយប្រុងប្រយ័ត្នលើបរិមាណ និងគុណភាព និងភាពសម្បូរបែបនៃធនធានធម្មជាតិ ការប៉ាន់ប្រមាណការប្រែប្រួលថ្លៃដើមនៃផលិតកម្ម និងតម្លៃប្រេងនៅពេលអនាគត។ ខណៈពេលដែលវិធីសាស្ត្រមានលក្ខណៈថយចុះ ទំនងជាអាចធានាបាននូវចំណូលរបស់រដ្ឋ នៅពេលដែលផលចំណេញពីប្រេង ឬឧស្ម័ន មិនសូវខ្ពស់ វិធីសាស្ត្រនេះ អាចធ្វើឲ្យវិនិយោគិនមានការរារែកក្នុងការវិនិយោគលើទីតាំងអណ្តូងរ៉ែតូចៗ។ ប៉ុន្តែវិធីសាស្ត្រនេះ នឹងមានភាពទាក់ទាញចំពោះ វិនិយោគគិន នៅពេលដែលប្រេង ឬឧស្ម័ន មានតម្លៃខ្ពស់ ហើយ លើកទឹកចិត្តដល់ការវិនិយោគ។ម្យ៉ាងវិញទៀត ប្រព័ន្ធដែលមានលក្ខណៈកើនឡើង អាចលើកទឹកចិត្តការវិនិយោគ នៅពេលប្រេង ឬឧស្ម័ន មានតម្លៃទាប ប៉ុន្តែមិនសូវមានភាពទាក់ទាញការវិនិយោគ នៅពេលប្រេង ឬឧស្ម័ន មានតម្លៃខ្ពស់ក្នុងទីផ្សារឡើយ[24] ហើយ រដ្ឋនឹងទទួលបានចំណូលពីធនធានប្រេង និងឧស្ម័ន ទាបជាងលទ្ធភាពដែលអាចទទួលបាន[25]។ ទោះជាយ៉ាងនេះក្តី ការកំណត់ពេលវេលាប្រមូលចំណូលរបស់រដ្ឋាភិបាលពីធនធានទាំងនេះ ក៏មានផលប៉ះពាល់ដូចគ្នា

[22]World Bank, *Contracts for Petroleum Development - Part 2*, 2.
[23]World Bank, *Contracts for Petroleum Development - Part 3.*
[24] ដូចជើងទំព័រខាងលើ
[25]World Bank, *Contracts for Petroleum Development - Part 2*, 2.

នឹងវិធីសាស្ត្រជ្រើសរើសក្នុងការចាត់ចែងផលចំណេញប្រេង និងឧស្ម័នដែរ។ ចំណុចទាំងនេះ នឹងត្រូវពិនិត្យក្នុងផ្នែកខាងក្រោមជាបន្តបន្ទាប់។

## ៣. ប្រព័ន្ធគ្រប់គ្រងចំណូលប្រេង និងឧស្ម័ន

ប្រព័ន្ធគ្រប់គ្រងចំណូលប្រេង និងឧស្ម័នរបស់ប្រទេសនីមួយៗមានសារៈសំខាន់ណាស់។ ការចំណាយធនធានរដ្ឋនៃប្រទេសសម្បូរធនធាន មានភាពមិនទៀងទាត់លើសពី៦០ភាគរយ ធៀបនឹងប្រទេសដែលខ្វះខាតធនធានធម្មជាតិដ៏សំខាន់ៗ[26]។ ភាពមិនទៀងទាត់ក្នុងការចំណាយ ជាសំខាន់គឺដោយសារការប្រែប្រួលខ្លាំងនៃតម្លៃធនធាន ហើយការឡើងចុះតម្លៃភ្លាមៗ អាចធ្វើឲ្យបាត់បង់ប្រាក់ចំណេញមួយរំពេចពីគម្រោងដែលរំពឹងថាអាចទទួលបានប្រាក់ចំណេញ ហើយនិងធ្វើឲ្យចំណូលរបស់រដ្ឋាភិបាល ធ្លាក់ចុះយ៉ាងខ្លាំង ។ ក្នុងន័យនេះ ប្រទេសផលិតប្រេង និងឧស្ម័នជ្រើសរើសប្រព័ន្ធគ្រប់គ្រងចំណូលណា ដែលធ្វើឲ្យផលចំណេញពីធនធានធម្មជាតិមានកម្រិតអតិបរមា ដែលនឹងធ្វើឲ្យសេដ្ឋកិច្ចក្នុងស្រុករួចផុតពីផលប៉ះពាល់នៃការប្រែប្រួលយ៉ាងគំហុកផ្នែកសេដ្ឋកិច្ចក្រៅប្រទេស ព្រមទាំងធ្វើឲ្យមានការរីកចម្រើនប្រកបដោយតុល្យភាព និងចីរភាពផ្នែកសេដ្ឋកិច្ចរយៈពេលវែង[27]។

ការគ្រប់គ្រងចំណូលរបស់ប្រេង និងឧស្ម័នរបស់រដ្ឋ ត្រូវបានបែងចែកជាបួនប្រភេទសំខាន់ៗ ដូចខាងក្រោម៖

១. ការចំណាយដែលកើនឡើងតាមចំណូលទទួលបានពីប្រេង និងឧស្ម័ន (Spend-as-you-go)
២. ទ្រព្យក្នុងដៃ (Bird in hand)
៣. សម្មតិកម្មចំណូលអចិន្ត្រៃយ៍ (Permanent Income Hypothesis)
៤. វិធីសាស្ត្រវិនិយោគប្រកបដោយចីរភាព (Sustainable Investing Tool)/ វិធីសាស្ត្របង្កើនការចំណាយជាបណ្តើរៗ (Gradual Scaling Approach)[28]

### ៣. ១. ការចំណាយកើនឡើងតាមចំណូលទទួលបានពីប្រេង និងឧស្ម័ន (Spend-as-you-go)

តាមវិធីសាស្ត្រនេះ ការចំណាយរបស់រដ្ឋាភិបាល គឺស្របតាមចំណូលពីប្រេង និងឧស្ម័នដែលទទួលបានក្នុងមួយឆ្នាំៗ។ នោះមានន័យថា នៅពេលដែលចំណូលពីប្រេង ឬឧស្ម័ន កើនឡើង

[26] IMF, *Macroeconomic Policy Frameworks for Resource-Rich Developing Countries* (Paris: IMF, 2012).p. 10.
[27] Steven Barnett and Rolando Ossowski, "Operational Aspects of Fiscal Policy in Oil-Producing Countries" (IMF, 2002).p. 8.
[28] Paul Collier, "The Political Economy of Natural Resources: Interdependence and Its Implications," 2009, https://depot.gdnet.org/newkb/submissions/paul%20collier_paper_p2.pdf; Andrew Berg et al., "Public Investment in Resource-Abundant Developing Countries," *IMF Economic Review* 61, no. 1 (2013): 92–129; DhaneshwarGhura and Catherine Pattillo, "Too Much of a Good Thing?," *Finance & Development* 50, no. 3 (2013): 9; IMF, *Macroeconomic Policy*; Roberto Iacono, "Is It Really Worse with a Bird in Hand? A Comparison of Fiscal Rules for Resource-Rich Economies" (Norwegian University of Science and Technology, 2012).

រដ្ឋាភិបាល នឹងបង្កើនការចំណាយរបស់ខ្លួន និងបញ្ចូលទុនវិនិយោគក្នុងសេដ្ឋកិច្ចទ្រង់ទ្រាយធំ ហើយវានឹងបង្កើនកំណើនសេដ្ឋកិច្ចមិនទាក់ទងនឹងប្រេង និងបង្កើនចំណូលពន្ធរបស់រដ្ឋាភិបាលពីវិស័យមិនទាក់ទងនឹងប្រេង។ ដូច្នេះ វិធីសាស្ត្រនេះ ផ្តល់លទ្ធភាពឲ្យរដ្ឋាភិបាលប្រើប្រាស់ធនធាននេះ ដើម្បីលើកកម្ពស់សុខមាលភាព និងបង្កើនចំណូលរបស់ប្រជាជន[29]។ ក៏ប៉ុន្តែ វិធីសាស្ត្រនេះ អាចសន្សំប្រាក់បានតិចតួចប៉ុណ្ណោះ ហើយភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងការចំណាយរបស់រដ្ឋាភិបាល, វិស័យសេដ្ឋកិច្ចធំៗដែលមានសក្តានុពល និងលទ្ធភាពសងបំណុលរបស់រដ្ឋ ជាមួយនឹងចំណូលប្រេង និងឧស្ម័ន ដែលមានការប្រែប្រួលខ្លាំង។ វិធីសាស្ត្រនេះ មានប្រសិទ្ធភាពខ្លាំង ក្នុងការដាក់បញ្ចូលចំណូលពីប្រេង និងឧស្ម័ន ក្នុងសេដ្ឋកិច្ចទ្រង់ទ្រាយធំ ក្នុងអំឡុងពេលតម្លៃប្រេង និងឧស្ម័ន បន្តកើនឡើងខ្ពស់ ក៏ប៉ុន្តែការធ្លាក់ចុះតម្លៃប្រេង និងឧស្ម័នយ៉ាងឆាប់រហ័ស ផ្តល់ផលប៉ះពាល់ដល់សេដ្ឋកិច្ចទាំងមូល ដែលបង្កឲ្យមានអស្ថេរភាពយ៉ាងខ្លាំង និងធ្វើឲ្យខាតបង់សេដ្ឋកិច្ចរយៈពេលវែង[30]។

<table>
<tr><th colspan="2">សេចក្តីសង្ខេបអំពីការចំណាយកើនឡើងតាមចំណូល<br>ទទួលបានពីប្រេង និងឧស្ម័ន (Spend-as-you-go)</th></tr>
<tr><td colspan="2">➢ ដាក់បញ្ចូលចំណូលប្រេង និងឧស្ម័នក្នុងថវិកាជាតិក្នុងថវិកាជាតិ និង<br>➢ ចំណូល ត្រូវបានចំណាយ នៅពេលទទួលបាន។</td></tr>
<tr><td>គុណសម្បត្តិ</td><td>គុណវិបត្តិ</td></tr>
<tr><td>ផលចំណេញពីធនធានប្រេង ត្រូវបានមើលឃើញភ្លាមៗ។</td><td>សន្សំប្រាក់បានតិចតួច</td></tr>
<tr><td>ការចំណាយរបស់រដ្ឋាភិបាលដែលបានបង្កើនជាដាក់បញ្ចូលទុនវិនិយោគក្នុងសេដ្ឋកិច្ចទ្រង់ទ្រាយធំ។</td><td>ឈានទៅរកអតិផរណាខ្ពស់</td></tr>
<tr><td>មានប្រសិទ្ធភាពក្នុងអំឡុងពេលប្រេង និងឧស្ម័នមានតម្លៃខ្ពស់។</td><td>ភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងសេដ្ឋកិច្ចទ្រង់ទ្រាយធំ ទៅនឹងប្រេង និងចំណូលពីប្រេងដែលមានការប្រែប្រួលភ្លាមៗ</td></tr>
<tr><td></td><td>មិនមានប្រសិទ្ធភាពក្នុងពេលតម្លៃប្រេងចុះថ្លៃ</td></tr>
</table>

## ៣.២ ទ្រព្យក្នុងដៃ (Bird-in-hand)

---

[29] Christine J. Richmond, Irene Yackovlev, and MsShu-Chun S. Yang, *Investing Volatile Oil Revenues in Capital-Scarce Economies: An Application to Angola*, 13-147 (International Monetary Fund, 2013), p. 12. http://books.google.com/books?hl=en&lr=&id=AL1ZLw8zPYwC&oi=fnd&pg=PP1&dq=%22The+Government%22+%22Parameter+Calibration%22+%22and+third+largest+economy.+The+civil+war,+which+ended+in+2002,%22+%22gaps+underscores+the+challenges+faced+by+capital-scarce+developing%22+%22prices+stayed+up,+leading+to+the+belief+that+they+were+permanent,+spending%22+&ots=bXVIFq3GYp&sig=BMgAkQXM5orrAaZM6U-tyhOzPq8.

[30] Ghura and Pattillo, "Too Much of a Good Thing?".

វាជាវិធីសាស្ត្រដែលមានលក្ខណៈប្រយ័ត្នប្រយែងបំផុត ដែលប្រទេសមួយ អាចជ្រើសរើសយកមកអនុវត្តក្នុងការគ្រប់គ្រងធនធានប្រេង និងឧស្ម័នរបស់ខ្លួន។ ជាមូលដ្ឋាន វិធីសាស្ត្រនេះ តម្រូវឲ្យរដ្ឋាភិបាលវិនិយោគប្រាក់ចំណូលពីប្រេង និងឧស្ម័នទាំងអស់ ចូលក្នុងទ្រព្យវិនិយោគ (Financial Assets)[31] ហើយចំណាយតែប្រាក់ចំណេញពីការវិនិយោគនោះតែប៉ុណ្ណោះ[32]។

តាមវិធីសាស្ត្រនេះ រដ្ឋាភិបាល មិនចាយវាយប្រាក់សួយសារ ,មិនបង្កើនប្រាក់កម្ចី ឬមិនសន្យាធ្វើការចំណាយផ្សេងៗ ដោយផ្អែកលើតម្លៃប៉ាន់ស្មាននៃប្រេង និងឧស្ម័ន ដែលអាចផលិតបានក្នុងពេលអនាគតឡើយ។ ក៏ប៉ុន្តែវិធីសាស្ត្រនេះ តម្រូវឲ្យរដ្ឋាភិបាល ដាក់បញ្ចូលក្នុងការរៀបចំផែនការ និងថវិការបស់ខ្លួននូវការប្រាក់ ដែលទទួលបានពីការវិនិយោគចំណូលពីប្រេង និងឧស្ម័ន នាពេលបច្ចុប្បន្នតែប៉ុណ្ណោះ និងតម្រូវឲ្យរដ្ឋាភិបាលរៀបចំផែនការចំណាយសម្រាប់ពេលអនាគត ដោយសន្និដ្ឋានថានឹងមិនមានចំណូលបន្ថែមពីប្រេង ឬឧស្ម័នទៀតទេ[33]។

វិធីសាស្ត្រនេះ អាចឲ្យរដ្ឋាភិបាលជៀសផុតពីលទ្ធភាពនៃការដួលរលំសេដ្ឋកិច្ច នៅពេលដែលតម្លៃធនធាន ឬធនធានបម្រុង មានកម្រិតទាបជាងការប៉ាន់ស្មាន។ ក៏ប៉ុន្តែ រដ្ឋាភិបាលត្រូវថ្លឹងថ្លែងផលប្រយោជន៍នេះជាមួយនឹងការបាត់បង់ឱកាសដ៏ធំ ដោយសារខកខានមិនបានធ្វើការវិនិយោគឲ្យបានសមស្របតាមបរិមាណប្រេង និងឧស្ម័នបម្រុង។ ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍ វិធីសាស្ត្រនេះអាចធ្វើឲ្យប្រជាជនជំនាន់នេះ មានកម្រិតជីវភាពទាបជាងប្រជាជនជំនាន់ក្រោយ។ នោះមានន័យថាសមត្ថភាពនាំមកជាមួយនូវការវិនិយោគខ្លះៗ មិនត្រឹមតែអាចសម្រាលភាពក្រីក្រតែប៉ុណ្ណោះទេ ថែមទាំងផ្តល់ផលចំណេញដ៏ធំចំពោះការអភិវឌ្ឍប្រទេសក្នុងរយៈពេលខ្លី និងរយៈពេលវែងផងដែរ[34]។

**សេចក្តីសង្ខេបអំពីវិធីសាស្ត្រទ្រព្យក្នុងដៃ (Bird in hand)**

- ជាវិធីសាស្ត្រដែលមានលក្ខណៈប្រយ័ត្នប្រយែងបំផុត
- ចាយវាយតែចំណូលការប្រាក់ដែលទទួលបានពីការវិនិយោគចំណូលប្រេង និងឧស្ម័នប៉ុណ្ណោះ
- មិនដាក់បញ្ចូលតម្លៃប៉ាន់ស្មាននៃប្រេង ឬឧស្ម័ន ដែលអាចផលិតបានក្នុងពេលអនាគតក្នុងថវិកាឡើយ។

[31] ឧទាហរណ៍ ទ្រព្យវិនិយោគ រួមមានភាគហ៊ុន ប្រាក់បញ្ញើធនាគារ សញ្ញាប័ណ្ណរបស់រដ្ឋ រូបិយបណ្ណបរទេស

[32] DariaZakharova and MsCharleen Gust, *Strengthening Russia's Fiscal Framework*, 12-76 (International Monetary Fund, 2012), p. 10. http://books.google.com/books?hl=en&lr=&id=DdlViXWhiHEC&oi=fnd&pg=PP2&dq=%22Hard+Landing,+Forceful+Response,+and+Difficult+Road+Ahead%22+%22Traditional+and+Nonoil+Fiscal+Indicators,+2004%E2%80%9310%22+%22the+rate+of+extraction+of+oil,+and+the+use+of+oil+revenue+have+significant%22+&ots=_CqBZ0TRPo&sig=rIw9vWoW3w_S4bysNVz14AeaoLg.

[33] Barnett and Ossowski, "Fiscal Policy."p. 14.

[34] Ghura and Pattillo, "Too Much of a Good Thing?".p. 11.

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| វិធីសាស្ត្រនេះ អាចឲ្យរដ្ឋាភិបាលជៀសផុតពីលទ្ធភាពនៃការដួលរលំហិរញ្ញវត្ថុ នៅពេលដែលតម្លៃធនធាន ឬធនធានបម្រុងមានកម្រិតទាបជាងការប៉ាន់ស្មាន។ | ត្រូវថ្លឹងថ្លែងផលប្រយោជន៍នេះជាមួយនឹងការបាត់បង់ឱកាសដ៏ធំ ដោយសារខកខានមិនបានធ្វើការវិនិយោគឲ្យបានសមស្របតាមបរិមាណប្រេង និងឧស្ម័នបម្រុង។ |
| កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់លើសេដ្ឋកិច្ចទ្រង់ទ្រាយធំ | ក្នុងប្រទេសកំពុងអភិវឌ្ឍ វិធីសាស្ត្រនេះ ធ្វើឲ្យប្រជាជនជំនាន់នេះ មានជីវភាពក្រីក្រជាងប្រជាជនជំនាន់ក្រោយ។ |
| កាត់បន្ថយលទ្ធភាពនៃការចាយវាយខ្ជះខ្ជាយចំណូលពីធនធានប្រេងនៅក្នុងដំណាក់កាលដំបូង | ការវិនិយោគនៅដំណាក់កាលដំបូង មិនត្រឹមតែអាចសម្រាលភាពក្រីក្រតែប៉ុណ្ណោះទេ ថែមទាំងផ្តល់ផលចំណេញដ៏ធំចំពោះការអភិវឌ្ឍប្រទេសក្នុងរយៈពេលខ្លី និងរយៈពេលវែងផងដែរ។ |

## ៣.៣ សម្មតិកម្មចំណូលអចិន្ត្រៃយ៍ (PIH)

វិធីសាស្ត្រសម្មតិកម្មចំណូលអចិន្ត្រៃយ៍ (PIH) ផ្អែកលើទ្រឹស្តីរបស់លោក Milton Friedman ជ័យលាភីរង្វាន់ណូបែលសេដ្ឋកិច្ច ដែលថ្លែងថា អ្នកសេដ្ឋកិច្ច មានគោលដៅកាត់តម្រឹមការប្រើប្រាស់ចំណូល និងការចំណាយរបស់ខ្លួន ក្នុងអំឡុងពេលទទួលបានចំណូលខ្ពស់ និងអំឡុងពេលទទួលបានចំណូលទាប ហើយជាពិសេស ត្រូវចំណាយជាមធ្យមនូវចំណូលសរុប ដែលបានរំពឹងទុកពីគម្រោងទាំងមូល[35]។ នៅពេលអនុវត្តចំពោះធនធានប្រេង ឬឧស្ម័នក្នុងប្រទេសមួយ វិធីសាស្ត្រសម្មតិកម្មចំណូលអចិន្ត្រៃយ៍ តម្រូវឲ្យរដ្ឋាភិបាល ចំណាយទឹកប្រាក់ចំនួនស្មើនឹងការប្រាក់ដែលទទួលបានពីធនធានប្រេង ឬឧស្ម័នសរុបរបស់ប្រទេសនោះតែប៉ុណ្ណោះ[36]។ ជាទូទៅ វិធីសាស្ត្រនេះ អាចសម្រេចបានតាមរយៈការវិនិយោគចំណូលទទួលបានពីឧស្ម័ន និងប្រេង ក្នុងមូលនិធិវិនិយោគរបស់រដ្ឋ (Sovereign Wealth Fund) ដែលអាចបង្កើតបានជាការប្រាក់។

វិធីសាស្ត្រនេះ អាចធ្វើឲ្យជៀសផុតពីអស្ថេរភាពដែលអាចកើតឡើង តាមរយៈការអនុវត្តវិធីសាស្ត្រចំណាយដែលកើនឡើងតាមចំណូលទទួលបានពីប្រេង និងឧស្ម័ន (Spend-as-you-go) និង

[35]Michael R. Darby, "The Permanent Income Theory of Consumption--A Restatement," *The Quarterly Journal of Economics* 88, no. 2 (May 1974): 228, doi:10.2307/1883070.

[36]Alonso Segura, *Management of Oil Wealth under the Permanent Income Hypothesis: The Case of São Tomé and Príncipe*, vol. 6 (International Monetary Fund, 2006), p. 8. http://books.google.com/books?hl=en&lr=&id=GesTSNZ0cVgC&oi=fnd&pg=PA4&dq=%222004+may+offer+the+best+chance+for+the+country+to+put+in+place+strong%22+%22sustainable+government+consumption+and+intergenerational+equity+while%22+%22of+US%243+billion.+These+figures+are+noticeably+high,+considering+that+for+2006+the%22+&ots=qhr_mh_XHl&sig=WT__K5XdcTEP6C76qKFDqKCy3Fg.

រក្សាបានទ្រព្យសម្បត្តិដើម្បីជាប្រយោជន៍ដល់មនុស្សជំនាន់ក្រោយ។ វិធីសាស្ត្រសម្មតិកម្មចំណូលអចិន្ត្រៃយ៍ ផ្តល់ប្រាក់សម្រាប់ការចំណាយច្រើនជាងវិធីសាស្ត្រទ្រព្យក្នុងដៃ (Bird in hand) និងរក្សាបានធនធានសម្រាប់ពេលអនាគត។ ក៏ប៉ុន្តែ មានការលើកឡើងថា ដោយហេតុថារដ្ឋាភិបាល ធ្វើការចំណាយទឹកប្រាក់ស្មើគ្នាទាំងមុនពេល និងក្រោយពេលផលិតប្រេង ឬឧស្ម័ននោះ វិធីសាស្ត្រនេះមើលរំលងភាពក្រីក្ររបស់ប្រជាជនក្នុងពេលបច្ចុប្បន្ន និងមើលរំលងផលចំណេញសេដ្ឋកិច្ចទ្រង់ទ្រាយធំ ទោះជារដ្ឋាភិបាល មានធនធានសម្រាប់ការចំណាយ ក្នុងស្ថានភាពនេះក៏ដោយ[37]។ បញ្ហានេះ នឹងត្រូវពិភាក្សាបន្ថែមក្នុងវិធីសាស្ត្រវិនិយោគប្រកបដោយចេរភាព (Sustainable Investing Tool)/ វិធីសាស្ត្របង្កើនចំណាយជាបណ្តើរៗ (Gradual Scaling Approach)។

<table>
<tr><th colspan="2">សេចក្តីសង្ខេបនៃវិធីសាស្ត្រសម្មតិកម្មចំណូលអចិន្ត្រៃយ៍</th></tr>
<tr><td colspan="2">➢ ចំណាយទឹកប្រាក់ចំនួនស្មើនឹងការប្រាក់ ដែលទទួលបានពីធនធានប្រេង ឬឧស្ម័នសរុបដែលបានប៉ាន់ស្មានរបស់ប្រទេសនោះ។<br>➢ ធ្វើការចំណាយជាមធ្យមនូវចំណូលសរុប ដែលទទួលបានពីគម្រោងទាំងមូល។<br>➢ អាចសម្រេចបានតាមរយៈការវិនិយោគចំណូលពីឧស្ម័ននិងប្រេងក្នុងមូលនិធិវិនិយោគរបស់រដ្ឋ (Sovereign Wealth Fund)។</td></tr>
<tr><td>គុណសម្បត្តិ</td><td>គុណវិបត្តិ</td></tr>
<tr><td>ជៀសផុតពីអស្ថេរភាពដែលអាចកើតឡើងតាមរយៈការអនុវត្តវិធីសាស្ត្រចំណាយកើនឡើងតាមចំណូលទទួលបានពីប្រេង និងឧស្ម័ន (Spend-as-you-go)</td><td>ដាក់កំហិតមិនឲ្យបង្កើនការចំណាយខ្ពស់ក្នុងដំណាក់កាលដំបូង</td></tr>
<tr><td>រក្សាបានធនធានសម្រាប់ប្រជាជនជំនាន់ក្រោយ</td><td>មើលរំលងភាពក្រីក្ររបស់ប្រជាជនក្នុងពេលបច្ចុប្បន្ន និងផលចំណេញសេដ្ឋកិច្ចទ្រង់ទ្រាយធំ ទោះជារដ្ឋាភិបាល មានធនធានសម្រាប់ការចំណាយ ក្នុងស្ថានភាពនេះក៏ដោយ។</td></tr>
<tr><td>ផ្តល់ប្រាក់ចំណាយខ្លះៗដើម្បីជាប្រយោជន៍ដល់ប្រជាជនជំនាន់បច្ចុប្បន្ន ដែលមានជីវិភាពក្រីក្រជាងប្រជាជនជំនាន់ក្រោយ</td><td></td></tr>
</table>

## ៣.៤ វិធីសាស្ត្របង្កើនចំណាយជាបណ្តើរៗ (Gradual Scaling Approach)

[37] Berg et al., "Public Investment in Resource-Abundant Developing Countries."p. 93.

វិធីសាស្ត្រនេះ ត្រូវបានហៅថាជា "វិធីសាស្ត្រវិនិយោគប្រកបដោយចេរភាព (Sustainable Investment Tool)" ហើយត្រូវបានចាត់ទុកថាជាចំណុចកណ្ដាលរវាងវិធីសាស្ត្រទ្រព្យក្នុងដៃ (Bird in hand) និងវិធីសាស្ត្រសម្មតិកម្មចំណូលអចិន្ត្រៃយ៍ (PIH) ពីព្រោះវិធីសាស្ត្រនេះ មានគោលដៅដាក់បញ្ចូលច្រើនជាងនូវចំណូលប្រេង និងឧស្ម័នក្នុងសេដ្ឋកិច្ចនៅដំណាក់កាលដំបូងឲ្យបានទាន់ពេលវេលា។ ដូចគ្នានឹងវិធីសាស្ត្រ Bird -in-hand ដែរ ទុនវិនិយោគសាធារណៈ ដែលទទួលបានពីចំណូលប្រេង និងឧស្ម័ន ត្រូវបានបង្កើនជាបណ្ដើរៗ ដើម្បីកាត់បន្ថយជាអតិបរមានូវអេតុល្យភាពសេដ្ឋកិច្ចក្នុងប្រទេស ដែលបណ្ដាលមកពីការបង្កើនការចំណាយភ្លាមៗរបស់រដ្ឋាភិបាល និងផ្ដល់ពេលគ្រប់គ្រាន់ឲ្យសេដ្ឋកិច្ចបង្កើនសមត្ថភាពដើម្បីស្រូបយកវិនិយោគទុនធំជាងមុន[38]។ ហើយដូចគ្នានឹងវិធីសាស្ត្រសម្មតិកម្មចំណូលអចិន្ត្រៃយ៍ (PIH) ដែរ តាមរយៈវិធីសាស្ត្រនេះ ចំណូលប្រេង និងឧស្ម័ន ត្រូវប្រើប្រាស់ដើម្បីបង្កើនទ្រព្យវិនិយោគ។ ជាទូទៅ មិនមានការដកប្រាក់ "មូលនិធិស្ថេរភាព (Stabilisation Fund)" ឡើយ។ នោះមានន័យថា នៅពេលដែលចំណូលប្រេង និងឧស្ម័ន ថយចុះ ការចំណាយរបស់រដ្ឋាភិបាល ក៏ត្រូវកាត់បន្ថយផងដែរ។ ទោះយ៉ាងនេះក្ដី ការប្រាក់ដែលទទួលបានពីមូលនិធិស្ថេរភាព ផ្ដល់ប្រភពចំណូលរយៈពេលវែងដល់រដ្ឋាភិបាល ដើម្បីដោះស្រាយផលប៉ះពាល់លើសេដ្ឋកិច្ចក្នុងប្រទេស និងកំណើនសេដ្ឋកិច្ច ដោយសារការឡើងចុះតម្លៃប្រេង និងឧស្ម័ន[39]។

តាមវិធីសាស្ត្រនេះ លទ្ធផលនៃការវិនិយោគ មិនលេចចេញជារូបរាងឆាប់រហ័ស ដូចវិធីសាស្ត្រចំណាយកើនឡើងតាមចំណូល (Spend-as-you-go) ឡើយ ក៏ប៉ុន្តែ វិធីសាស្ត្រនេះ អាចផ្ដល់ទុនវិនិយោគ និងប្រើប្រាស់ចំណូលច្រើនជាង ដើម្បីជាប្រយោជន៍ដល់ប្រជាជននាពេលបច្ចុប្បន្ន និងផ្ដល់ផលប្រយោជន៍សង្គម និងសេដ្ឋកិច្ចដល់ប្រទេសកំពុងអភិវឌ្ឍ ច្រើនជាងវិធីសាស្ត្រផ្សេងទៀត[40]។ ឯកសារស្រាវជ្រាវជាច្រើន លើកឡើងថា សេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍ ប្រឈមនឹងវដ្ដនៃការចម្រើនលូតលាស់ និងការធ្លាក់ចុះ និងងាយទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារដំណើរឡើងចុះបែបនេះ ដូច្នេះចាំបាច់ត្រូវបង្កើតឲ្យមានមូលនិធិស្ថេរភាព (Stabilisation Fund) ដើម្បីជួយធ្វើឲ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចេរភាព[41]។

វិធីសាស្ត្រគ្រប់គ្រងចំណូលប្រេង និងឧស្ម័ន និងការចំណាយបែបនេះ កំពុងត្រូវបានអនុវត្តដោយជោគជ័យក្នុងប្រទេសទីម័រខាងកើត[42] ហើយដោយសារមូលហេតុស្រដៀងគ្នានេះ វិធីសាស្ត្រនេះ អាចមានលក្ខណៈសមស្របចំពោះប្រទេសកម្ពុជាផងដែរ ពីព្រោះវិធីសាស្ត្រនេះ ផ្ដល់ទាំងស្ថេរភាព និងធនធានរយៈពេលយូរ តាមរយៈការបង្កើតប្រាក់សន្សំដ៏រឹងមាំ និងបង្កើនការចំណាយក្នុងប្រទេស

---

[38]Ghura and Pattillo, "Too Much of a Good Thing?"; Berg et al., "Public Investment in Resource-Abundant Developing Countries." p. 11

[39]Richmond, Yackovlev, and Yang, *Investing Volatile Oil Revenues in Capital-Scarce Economies*.p. 12.

[40]Berg et al., "Public Investment in Resource-Abundant Developing Countries."P. 93.

[41]Ghura and Pattillo, "Too Much of a Good Thing?".p.11.

[42] World Bank and Independent Evaluation Group, *Timor-Leste Country Program Evaluation, 2000-2010: Evaluation of the World Bank Group Program* (Washington, D.C.: World Bank Group, Independent Evaluation Group, 2011).

ក្នុងកម្រិតថេរមួយ។ ក្នុងប្រទេសដែលមានការអភិវឌ្ឍកម្រិតទាប ដូចប្រទេសកម្ពុជា ការបង្កើនការចំណាយជាបណ្តើរៗ មានភាពចាំបាច់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមិនទាក់ទងនឹងប្រេងរបស់ប្រទេសនេះ ដែលនឹងបង្កើនលទ្ធភាពនៃការចំណាយ និងវិនិយោគទុនក្នុងប្រទេស ដើម្បីជម្រុញការអភិវឌ្ឍប្រទេស និងកាត់បន្ថយភាពក្រីក្រ។

**សេចក្តីសង្ខេបនៃវិធីសាស្ត្របង្កើនការចំណាយជាបណ្តើរៗ (Gradual Scaling Approach)**

- ចាត់ទុកថាជាចំណុចកណ្តាលរវាងវិធីសាស្ត្រទ្រព្យក្នុងដៃ (Bird in hand) និងវិធីសាស្ត្រសម្មតិកម្មចំណូលអចិន្ត្រៃយ៍ (PIH)
- ចំណូលប្រេង និងឧស្ម័ន ត្រូវបានប្រើប្រាស់ ដើម្បីបង្កើន "មូលនិធិស្ថេរភាព (Stabilisation Fund)" នៃទ្រព្យវិនិយោគ
- "មូលនិធិស្ថេរភាព" មិនអាចដកបានឡើយ។ ដូច្នេះ មានន័យថា នៅពេលដែលចំណូលប្រេង និងឧស្ម័ន ថយចុះ ការចំណាយរបស់រដ្ឋាភិបាលក៏ត្រូវកាត់បន្ថយផងដែរ។
- ការប្រាក់ដែលទទួលបាន ផ្តល់ជាប្រភពចំណូលរយៈពេលវែងដល់រដ្ឋាភិបាល និងដោះស្រាយផលប៉ះពាល់នៃតម្លៃប្រេងដែលមានការប្រែប្រួលភ្លាមៗ។

| **គុណសម្បត្តិ** | **គុណវិបត្តិ** |
|---|---|
| អាចយកមកចំណាយដើម្បីជាប្រយោជន៍របស់ប្រជាជននាពេលបច្ចុប្បន្ន | ត្រូវការស្ថាប័នរដ្ឋរឹងមាំដើម្បីគ្រប់គ្រងមូលនិធិឲ្យបានជោគជ័យ |
| ការចំណាយរបស់រដ្ឋាភិបាល កើនឡើងជាបណ្តើរៗ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចដែលមិនទាក់ទងនឹងប្រេង។ | មើលរំលងភាពក្រីក្ររបស់ប្រជាជនក្នុងពេលបច្ចុប្បន្ន និងផលចំណេញសេដ្ឋកិច្ចទ្រង់ទ្រាយធំ ទោះជារដ្ឋាភិបាល មានធនធានសម្រាប់ចំណាយ ក្នុងស្ថានភាពនេះក៏ដោយ។ |
| កាត់បន្ថយអស្ថេរភាពចំណូល | ត្រូវការវិនិយោគ ដែលមានគោលដៅច្បាស់លាស់រយៈពេលវែង ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចដែលមិនទាក់ទងនឹងប្រេង។ |
| កាត់បន្ថយអស្ថេរភាពចំណូល | មិនលេចចេញជាលទ្ធផលភ្លាមៗ ដូចវិធីសាស្ត្រការចំណាយដែលកើនឡើងតាមចំណូលទទួលបានពីប្រេង និងឧស្ម័ន (Spend-as-you-go) ឡើយ។ |

# ៤. ហានិភ័យនយោបាយ និងសេដ្ឋកិច្ច និងភាពលានុវត្តភាព ដែលជាប់ទាក់ទង នឹងចំណូលទទួលបានពីប្រេង និងឧស្ម័ន

## ៤.១ ហានិយភ័យ

ទ្រឹស្តីនយោបាយ និងសេដ្ឋកិច្ចទូទៅ សន្និដ្ឋានថាប្រទេសដែលសម្បូរធនធានធម្មជាតិ ដូចជាប្រេង និងឧស្ម័ន មិនសូវមានលទ្ធផលល្អទាក់ទងនឹងកំណើនសេដ្ឋកិច្ច អំពើពុករលួយ និងស្ថេរភាពនយោបាយឡើយ[43]។

អ្វីដែលគេហៅថា "ជំងឺហូឡង់ (Ducth Disease)"នោះ ជាស្ថានភាពមួយទាក់ទងនឹងការលើកឡើងខាងលើនេះ ដោយសារប្រទេសហូឡង់ បានឆ្លងកាត់ផលលំបាកសេដ្ឋកិច្ច ក្រោយពេលផលិតឧស្ម័ននៅសមុទ្រខាងកើត "North Sea Gas"។ ជំងឺសេដ្ឋកិច្ចនេះ កើតឡើង ដោយសារការហូរចេញធនធានធម្មជាតិដ៏មានតម្លៃ និងការហូរចូលប្រាក់ដុល្លាយ៉ាងឆាប់រហ័ស និងការកើនតម្លៃរូបិយប័ណ្ណរបស់ប្រទេសជាបន្តបន្ទាប់។ កត្តានេះ បណ្តាលឲ្យវិស័យសេដ្ឋកិច្ចផ្សេងៗ ដូចជាផលិតកម្មវាយនភ័ណ្ឌ មិនសូវមានលក្ខណៈប្រកួតប្រជែងក្នុងទីផ្សារនាំចេញ[44]។ ទស្សនៈទាននេះ ត្រូវបានលើកឡើងក្នុងឯកសារស្រាវជ្រាវដែលត្រូវបានស្គាល់យ៉ាងទូលំទូលាយរបស់លោកសាស្ត្រាចារ្យ Jeffery Sachs ។ ឯកសារស្រាវជ្រាវនោះ លើកឡើងថាយោងតាមទិន្នន័យសេដ្ឋកិច្ច ប្រទេសដែលសម្បូរធនធានធម្មជាតិ មានកំណើនសេដ្ឋកិច្ចទាបជាងប្រទេសឯទៀត[45]។ លោកសាស្ត្រាចារ្យ Sachs សន្និដ្ឋានថាស្ថានភាពនេះ កើតឡើង ដោយសារតម្លៃនៃធនធានធម្មជាតិ ធ្វើឲ្យសកម្មភាពសេដ្ឋកិច្ចងាកចេញពីការផលិត ដែលបណ្តាលឲ្យរារាំងការតភ្ជាប់សេដ្ឋកិច្ច និងការបង្កើតកម្លាំងពលកម្ម វត្ថុធាតុដើម និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានាសម្រាប់ការផលិតផលិតផលផ្សេងៗ។ មានការយល់ឃើញថាស្ថានភាពនេះ អាចបង្កគ្រោះថ្នាក់ ពីព្រោះសកម្មភាពសេដ្ឋកិច្ច ដែលបានបង្កើតឡើងតាមរយៈផលិតកម្មផ្សេងៗ ជាទូទៅត្រូវបានចាត់ទុកថាជាយន្តការសំខាន់មួយ ដើម្បីអភិវឌ្ឍឧស្សាហកម្ម និងបណ្តុះបណ្តាលកម្លាំងការងារជំនាញ ដែលមានសារៈសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច[46]។

ការសិក្សាថ្មីៗនេះ បានកំណត់ប្រើពាក្យ "បណ្តាសាធនធាន" ដើម្បីពិពណ៌នាអំពីវិស័យប្រេង និងឧស្ម័ន។ លោកសាស្ត្រាចារ្យ Michael Ross កត់សម្គាល់ថា "ភូគព្ភសាស្ត្រល្អ បណ្តាលឲ្យមាននយោបាយអាក្រក់។"[47] លោកសាស្ត្រាចារ្យ Ross បានសិក្សាឃើញថាចាប់តាំងពីឆ្នាំ ១៩៨០ មកប្រទេសដែលសម្បូរប្រេង និងឧស្ម័ន ហើយមានស្ថាប័នរឹងមាំ ជាប្រទេសអភិវឌ្ឍ និងមានចំណូលខ្ពស់

---

[43]RabahArezki and Markus Brückner, *Oil Rents, Corruption, and State Stability: Evidence from Panel Data Regressions*, IMF Working Paper (Washington DC: IMF, 2009), http://www.sciencedirect.com/science/article/pii/S0014292111000316.
[44]The Economist, "The Curse of Oil."
[45]Jeffrey Sachs and Andrew Warner, *Natural Resource Abundance and Economic Growth*, Working Paper (Cambridge, MA: National Bureau of Economic Research, 1995), http://www.nber.org/papers/w5398.pdf. pp. 2-7.
[46]ដូចជើងទំព័រខាងលើ
[47]Ross Michael, *The Oil Curse* (Princeton: Princeton University Press, 2012).p. 2.

ដូចជាប្រទេសកាណាដា ប្រទេសន័រវេស ឬសហរដ្ឋអាមេរិក បានជៀសផុតពីផលប៉ះពាល់អវិជ្ជមានពីផលិតកម្មប្រេង និងឧស្ម័ន។ ផ្ទុយទៅវិញ ប្រទេសដែលមានចំណូលពីទាបទៅមធ្យម និងមានការអភិវឌ្ឍតិចតួច ទទួលរងផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំង។ តាមរយៈការចងក្រងទិន្នន័យដែលទទួលបានពីប្រទេសចំនួន១៧០ លោកសាស្ត្រាចារ្យ Ross រកឃើញថាប្រទេសកំពុងអភិវឌ្ឍដែលសម្បូរប្រេង និងឧស្ម័ន ងាយរងគ្រោះដោយសារអំពីផ្តាច់ការ ឬ សង្គ្រាមស៊ីវិលទ្វេរដង, មានអស្ថេរភាពហិរញ្ញវត្ថុក្នុងកម្រិតខ្ពស់ជាង និងមានពិន្ទុសន្ទស្សន៍នៃការអភិវឌ្ឍរបស់ប្រជាជន (Human Development Index)[48]ទាបជាង ធៀបនឹងប្រទេសឯទៀត[49]។

ការប្រែប្រួលតម្លៃឧស្ម័នធ្យូងថ្ម ក៏អាចបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ប្រទេសផងដែរ។ នៅពេលវាមានតម្លៃខ្ពស់ វាជាការសមស្រប ដែលប្រទេសមួយ ខ្ចីប្រាក់ និងធ្វើវិនិយោគទ្រង់ទ្រាយធំក្នុងការរុករក និងបង្កើនសមត្ថភាពក្នុងការនាំចេញឧស្ម័នធ្យូងថ្ម ហើយវាជាក៏ការសមស្របផងដែរដែលប្រទេសក្រីក្រ បង្កើនការចំណាយលើការងារសង្គមកិច្ច ដើម្បីឲ្យរដ្ឋាភិបាលទទួលបានប្រជាប្រិយភាព និងកាត់បន្ថយភាពក្រីក្រ ក៏ប៉ុន្តែ យុទ្ធសាស្ត្រនេះ មានហានិយភ័យខ្ពស់ណាស់ ពីព្រោះវាតម្រូវឲ្យរក្សាតម្លៃខ្ពស់នៃប្រេង និងឧស្ម័ន ។ នោះមានន័យថារដ្ឋអាចក្ស័យទុនភ្លាមៗ នៅពេលដែលតម្លៃប្រេងធ្លាក់ចុះមកត្រឹមតម្លៃដើម។[50]

ហានិយភ័យចុងក្រោយដែលត្រូវពិចារណានោះ គឺការប៉ុនប៉ងចាយវាយចំណូលប្រេងដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីឧបត្ថម្ភធនឥន្ធនៈ។ គោលនយោបាយកាត់បន្ថយតម្លៃឥន្ធនៈបែបនេះ ជារឿយៗ មានប្រជាប្រិយភាពខ្លាំងក្នុងចំណោមប្រជាជនទូទៅ ក៏ប៉ុន្តែគោលនយោបាយទាំងនេះ ត្រូវចំណាយប្រាក់ច្រើនពេក បង្កើតភាពខ្វះខ្វាយ និងងាយកើតមានអំពើពុករលួយ។ ហានិយភ័យនានា រួមមានការលើកទឹកចិត្តឲ្យមានការរត់ពន្ធឥន្ធនៈ ការផ្តល់ការឧបត្ថម្ភធនឥន្ធនៈសម្រាប់យានយន្តរបស់អ្នកមានជីវភាពធូរធារ ដោយមិនផ្តោតគោលដៅចំពោះអ្នកទទួលប្រយោជន៍ជាក់លាក់ និងការជំរុញឲ្យកើតមានអំពើពុករលួយក្នុងកម្រិតខ្ពស់ ពីព្រោះការឧបត្ថម្ភធន មិនបានដល់ដៃអ្នកប្រើប្រាស់ទាំងស្រុងឡើយ។ មានការប៉ាន់ស្មានថា អំពើពុករលួយបែបនេះ ធ្វើឲ្យប្រទេសនីហ្សេរីយ៉ាខាតបង់ទឹកប្រាក់ជិត ១២ ពាន់លានដុល្លា ពីឆ្នាំ ២០០៩ ដល់ឆ្នាំ២០១១។[51]

---

[48]The HDI was developed as a holistic indicator of a country's development, which takes into account a number of factors which influence the population's quality of life, as well as economic factors. For more information see: http://hdr.undp.org/en/content/human-development-index-hdi; and http://www.kh.undp.org/content/dam/cambodia/docs/PovRed/2013HDRAnalysisonCambodia.pdf

[49]Michael, *The Oil Curse*. pp. 1-27.

[50]Paul Stevens and Matthew Hulbert, *Oil Prices: Energy Investment, Political Stability in the Exporting Countries and OPEC's Dilemma* (Chatham House, 2012), http://www.chathamhouse.org/sites/default/files/public/Research/Energy,%20Environment%20and%20Development/1012pp_opec.pdf. pp. 8-9.

[51]Sarah Kent, "Nigeria Loses Billions to Inefficiencies in Oil Sector - Watchdog," *Wall Street Journal*, July 30, 2013, sec. Markets, http://online.wsj.com/news/articles/SB10001424127887324809004578637443141740504.

## ៤.២ ការបញ្ចៀសហានិយភ័យ

### សារៈសំខាន់នៃស្ថាប័នដែលមានសមត្ថភាព

ការបញ្ចៀសហានិយភ័យ ជាបឋមពឹងផ្អែកលើការអភិវឌ្ឍស្ថាប័នរឹងមាំ និងមានស្ថេរភាព ដែលមានភាពចាំបាច់ដើម្បីរៀបចំបង្កើត និងអនុវត្តគោលនយោបាយរយៈពេលវែង និងមានស្ថេរភាព និងការពារប្រឆាំងនឹងអំពើពុករលួយ។ លោកសាស្ត្រាចារ្យ Jeffery Frankel ដែលបង្រៀនមុខវិជ្ជាម៉ាក្រូសេដ្ឋកិច្ចនៅសាកលវិទ្យាល័យហាវ៉ាដ (Harvard) កត់សម្គាល់ថា "គុណភាពស្ថាប័ន ជាកត្តាសំខាន់បំផុតក្នុងការកំណត់ថាតើប្រទេសផលិតប្រេង និងឧស្ម័នណា ទទួលជោគជ័យ និងប្រទេសណា មិនទទួលជោគជ័យ[52]។"

ស្ថាប័នទាំងនេះ រួមមានអង្គភាពប្រមូលពន្ធដែលមានសមត្ថភាព, អង្គភាពឯករាជ្យដែលមានសមត្ថភាពគ្រប់គ្រងគោលនយោបាយសារពើពន្ធ និងការប្រើប្រាស់ចំណូលទទួលបានពីធនធានឲ្យបានសមស្រប។ ការគាំពារស្ថាប័ននានា ដូចជាស្ថាប័នតុលាការ និងអង្គភាពប្រឆាំងអំពើពុករលួយ ក៏មានភាពចាំបាច់ផងដែរ ដើម្បីទប់ស្កាត់ការចាយវាយប្រាក់សន្សំ និងចំណូលដោយមិនមានចេរភាព ដើម្បីប្រយោជន៍នយោបាយ [53]។

### ការធ្វើឲ្យជៀសផុតពីបណ្តាសាធនធាន

មិនមានរូបមន្តណាដែលល្អឥតខ្ចោះ ដើម្បីធ្វើឲ្យជៀសផុតពីបណ្តាសាធនធានទេ ពីព្រោះប្រទេសនីមួយៗមានស្ថានភាពខុសៗគ្នា ដូច្នេះតម្រូវឲ្យមានវិធីដោះស្រាយដាច់ដោយឡែកពីគ្នា។ ការអភិវឌ្ឍស្ថាប័នឲ្យមានភាពរឹងមាំ អាចផ្តល់ជាគោលនយោបាយចាំបាច់ ដើម្បីធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេស និងដើម្បីអភិវឌ្ឍគោលនយោបាយសារពើពន្ធដើម្បីទប់ទល់នឹងវិបត្តិសេដ្ឋកិច្ច (counter-cyclical fiscal policies)។ គោលនយោបាយនេះ មានភាពចាំបាច់ដើម្បីធ្វើការបត់បែនទៅតាមអំឡុងពេលដែលប្រេងឡើងថ្លៃខ្ពស់ និងអំឡុងពេលដែលប្រេងចុះថ្លៃទាប និងធ្វើឲ្យរួចផុតពីស្ថានភាពអាក្រក់បំផុត ដែលបានកើតឡើងក្នុងករណីជំងឺហូឡង់ Dutch Disease)[54]។ វិធានការអភិបាលកិច្ចល្អ អាចឲ្យប្រទេសមួយធ្វើការអភិវឌ្ឍដោយចេរភាព ក្នុងរយៈយូរអង្វែង បន្ទាប់ពីធនធានធម្មជាតិរបស់ប្រទេសនោះ រីងស្ងួត [55]។

---

[52] Frankel, *The Natural Resources Curse*. pp. 9-10.
[53] Yanchun Zhang and Office of Development Studies, UNDP, "Managing Resource Revenue in the Context of Increasing Commodity Price Volatility" (presented at the International Conference: Avoiding the Resource Curse - Managing Extractive Industries for Human Development, Ulaanbaatar: UNDP, 2011), http://www.undp.mn/mining/index.php?page=6.
[54] Michael, *The Oil Curse*. pp. 223-254., Helen Clark, "Avoiding the Resource Curse: Managing Extractive Industries for Human Development," in *Keynote Speech* (presented at the Avoiding the Resource Curse: Managing Extractive Industries for Human Development, Ulaanbaatar: UNDP, 2011), http://www.undp.org/content/undp/en/home/presscenter/speeches/2011/10/20/helen-clark-avoiding-the-resource-curse-managing-extractive-industries-for-human-development-/.
[55] Clark, "Avoiding the Resource Curse."

## គំនិតផ្តួចផ្តើមដើម្បីឲ្យមានតម្លាភាពក្នុងឧស្សាហកម្មរុករក

ធនាគារពិភពលោក បានកំណត់ថា ការមានតម្លាភាពគ្រប់គ្រាន់ មានសារៈសំខាន់បំផុតក្នុងការជួយជ្រោមជ្រែងដល់ការអភិវឌ្ឍ និងកិច្ចដំណើរការនៃស្ថាប័នទាំងនេះ[56]។ មធ្យោបាយមួយដើម្បីធ្វើឲ្យមានតម្លាភាព គឺអាចធ្វើបានតាមរយៈការចូលរួមក្នុងគម្រោងគោលការណ៍គំនិតផ្តួចផ្តើមឲ្យមានតម្លាភាពក្នុងឧស្សាហកម្មនិស្សារណកម្ម (EITI) ដែលគាំទ្រដោយធនាគារពិភពលោក និងអង្គការសហប្រជាជាតិ[57]។ គម្រោង EITI ជួយសម្រួល និងតម្រូវឲ្យរដ្ឋាភិបាល និងក្រុមហ៊ុនផលិតប្រេងបង្ហាញព័ត៌មានហិរញ្ញវត្ថុទាក់ទងនឹងប្រាក់សួយសារ ប្រាក់កំរៃ ការបង់ប្រាក់ ពន្ធដែលបានបង់ ព័ត៌មានមួយចំនួនទាក់ទងនឹងការផលិតកម្ម និងលក្ខខណ្ឌនៃកិច្ចសន្យា និងរៀបចំឲ្យមានសវនករឯករាជ្យ និងគួរឲ្យទុកចិត្តបាន[58]។ EITI ទទួលបានការគាំទ្រយ៉ាងទូលំទូលាយជាអន្តរជាតិ និងពីវិស័យឧស្សាហកម្ម ព្រមទាំងសមាជិករបស់ខ្លួន[59]។

## គោលនយោបាយដែលពាក់ព័ន្ធរបស់សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ក្នុងការលើកកម្ពស់តម្លាភាពប្រេង ឬឧស្ម័ន

គោលនយោបាយរបស់ប្រទេសសំខាន់ៗ ដែលមានឥទ្ធិពលលើកិច្ចដំណើរការរបស់ក្រុមហ៊ុនរុករកប្រេង និងឧស្ម័នធំៗ កំពុងបង្កើតឲ្យមានសម្ពាធប្រហាក់ប្រហែលគ្នា ទាក់ទងនឹងតម្លាភាព និងគណនេយ្យភាព។ ច្បាប់ក្នុងសហរដ្ឋអាមេរិក តម្រូវឲ្យក្រុមហ៊ុនឧស្សាហកម្មរុករកប្រេង ដែលចុះបញ្ជីក្នុងសហរដ្ឋអាមេរិកទាំងអស់ ប្រកាសជាសាធារណៈនូវរាល់ការចំណាយប្រាក់ដល់រដ្ឋាភិបាលនៃប្រទេសនានា។ ច្បាប់ស្រដៀងគ្នានេះ កំពុងត្រូវបានយកមកពិចារណា ក្នុងសហភាពអឺរ៉ុបផងដែរ [60]។

## ៤.៣ ភាពលាន់ទត្ថភាព

ការផលិតប្រេង និងឧស្ម័ន ដែលមានការគ្រប់គ្រងត្រឹមត្រូវ ផ្តល់ឱកាសដ៏ធំក្នុងការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ច។ ឱកាសទាំងនេះ រួមមានការអភិវឌ្ឍឧស្សាហកម្ម ដែលអាចផ្គត់ផ្គង់ដល់ផលិតកម្មប្រេង និងឧស្ម័ន ឬការអភិវឌ្ឍឧស្សាហកម្មដែលទទួលបានការឧបត្ថម្ភធនអគ្គិសនី និងការផ្គត់ផ្គង់ផលិតវត្ថុជាតុដើម និងធនធានចាំបាច់សម្រាប់វិស័យឧស្សាហកម្ម។ ឧទាហរណ៍ ការអភិវឌ្ឍរោងចក្រផលិតសារជាតុគីមីសំយោគពីប្រេង អាចឲ្យប្រទេសកម្ពុជាមានលទ្ធភាពផលិតសរសៃអំបោះសំយោគ ដែលអាចយកមកប្រើប្រាស់ក្នុងវិស័យវាយនភណ្ឌបាន។ នោះនឹងបង្កើនការផលិតវត្ថុជាតុ

---

[56]World Bank, *Extractive Industries Transparency Initiative*, Cambodia Oil & Gas Briefing Notes (Washington DC: World Bank, 2007), http://siteresources.worldbank.org/INTOGMC/Resources/cambodia_oil_gas_newsletter_15.pdf.p. 1.

[57]ដូចជើងទំព័រខាងលើ

[58]EITI, *EITI Rules* (Oslo: EITI), accessed July 28, 2014, http://eiti.org/document/rules.p. 11.

[59]EITI, *EITI Fact Sheet* (Oslo: EITI), accessed July 28, 2014, http://eiti.org/document/factsheet.

[60]"IISS," accessed July 28, 2014, http://www.iiss.org/en/iiss%20voices/blogsections/iiss-voices-2013-1e35/march-2013-6eb6/avoiding-resource-curse-65e7.

ដើមក្នុងប្រទេស ដើម្បីជម្រុញផលិតកម្មនានា ហើយជាបណ្តើរៗ អាចផលិតបាននូវផលិតផលកាន់តែទំនើប។ ការផលិត កាន់តែមានភាពងាយស្រួលតាមរយៈការផ្គត់ផ្គង់អគ្គិសនីដែលមានតម្លៃទាប និងអាចទុកចិត្តបានពីរោងចក្រអគ្គិសនីប្រើឧស្ម័នធម្មជាតិ។

ឧទាហរណ៍ គុណភាពវិស្វកម្មក្នុងប្រទេស អាចត្រូវបានបង្កើន តាមរយៈការភ្ជាប់ទំនាក់ទំនងឱកាសការងារនៅតាមរោងចក្រទាក់ទងនឹងប្រេង និងឧស្ម័ន ទៅនឹងកម្មវិធីសិក្សានៅតាមសាកលវិទ្យាល័យក្នុងប្រទេស។ បើសិនគ្រប់គ្រងបានជោគជ័យ យើងអាចបង្កើតបានធនធានដែលមានជំនាញសមស្របមួយក្រុម ដើម្បីបំពេញតម្រូវការធនធានមនុស្សកម្រិតឧត្តមសិក្សា ដែលកើនឡើងស្របតាមកំណើននៃតម្រូវការការងារក្នុងឧស្សាហកម្មទាក់ទងនឹងប្រេង និងឧស្ម័ន។ ទន្ទឹមនឹងនោះធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ នឹងកើនឡើងក្នុងសេដ្ឋកិច្ចឧស្សាហកម្មដែលអាចជម្រុញកំណើនសេដ្ឋកិច្ច និងបំពេញតម្រូវការធនធានពលកម្មជំនាញ។

វិធីសាស្ត្ររយៈពេលយូរអង្វែង និងមានចេរភាពបំផុតនោះ គឺការប្រើប្រាស់ចំណូលប្រេង និងឧស្ម័ន សម្រាប់ការវិនិយោគ ដើម្បីធ្វើពិពិតកម្មវិស័យសេដ្ឋកិច្ចដែលមិនទាក់ទងនឹងប្រេង ឬឧស្ម័ន និងកាត់បន្ថយជាអតិបរមានូវការប្រឈមរបស់រដ្ឋទៅនឹងការប្រែប្រួលតម្លៃប្រេង និងឧស្ម័ន ។ វិធីសាស្ត្រនេះ អាចសម្រេចបានតាមរយៈមធ្យោបាយមួយចំនួន ដូចជាការវិនិយោគគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈសមស្រប និងការបណ្តុះបណ្តាលធនធានមនុស្សកម្រិតឧត្តមសិក្សា។ លើសពីនេះទ្រព្យដែលទទួលបានពីធនធានប្រេងនិងឧស្ម័ន អាចយកមកប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្ស ដើម្បីកាត់បន្ថយភាពក្រីក្រ បង្កើនចំណូលរដ្ឋជាអចិន្ត្រៃយ៍ ឬផ្ទេរប្រាក់ចំណេញដោយផ្ទាល់ទៅឲ្យប្រជាពលរដ្ឋ ដូចករណីនៅអាល់បឺតា (Alberta) ឬអាឡាស់ស្កា (Alaska) តាមរយៈមូលនិធិវិនិយោគរបស់រដ្ឋ (Sovereign Wealth Fund)[61]។ នោះជាឱកាសដ៏ធំពីព្រោះវាអាចបង្កើនចំណូល និងស្ថេរភាពសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ និងលើកកម្ពស់គុណភាពជីវិតប្រជាជនឲ្យមានភាពប្រសើរឡើង។

## ការរំពឹងទុកនានាពីធនធានឧស្ម័ន

ឱកាសដែលឧស្ម័នធម្មជាតិផ្តល់ឲ្យប្រទេសកម្ពុជា មានលក្ខណៈខុសពីឱកាសផ្តល់ដោយប្រេងពីព្រោះ វាមានការលំបាកយ៉ាងខ្លាំងក្នុងការដឹកជញ្ជូនឧស្ម័នធម្មជាតិជាងការដឹកជញ្ជូនប្រេង។ បំពង់បង្ហូរ អាចប្រើប្រាស់បានសម្រាប់ចម្ងាយជិត ឬទិសដៅសំខាន់ៗ ដូចជារោងចក្រថាមពលឧស្ម័ន។ ដូច្នេះ ជាទូទៅ វាចាំបាច់ត្រូវពង្រាវឧស្ម័ន ដើម្បីធ្វើការដឹកជញ្ជូនចម្ងាយឆ្ងាយ។ វាមិនមានផលចំណេញសេដ្ឋកិច្ចក្នុងការរុករកឧស្ម័នឡើយ បើសិនមិនអាចទទួលបានឧស្ម័នក្នុងបរិមាណដ៏ច្រើនទេនោះ ពីព្រោះការពង្រាវឧស្ម័ន ត្រូវការចំណាយប្រាក់រាប់ពាន់លានដុល្លា ដើម្បីសាងសង់ហេដ្ឋរចនា

[61]Jeffrey Sachs, "How to Handle the Macroeconomics of Oil Wealth," in *Escaping the Resource Curse*, ed. Macartan Humphreys, Jeffrey Sachs, and Joesph E. Stiglitz (New York: Columbia University Press, n.d.). pp. 173-94.

សម្ព័ន្ធនៅស្ថានីយ៍ដឹកចេញ និងដឹកចូល និងការដឹកជញ្ជូនជាពិសេស។ ក៏ប៉ុន្តែ ឧស្ម័នធម្មជាតិ បំពុលបរិស្ថានតិចតួចបំផុត និងមានលក្ខណៈសន្សំសំចៃច្រើនបំផុត ធៀបនឹងធ្យូងថ្ម ឬប្រេង ។ នោះមានន័យថាជាសក្តានុពល ឧស្ម័នបម្រុងរបស់កម្ពុជា អាចផ្តល់ថាមពលដល់រោងចក្រថាមពលឧស្ម័នធម្មជាតិ ឬផ្តល់វត្ថុធាតុដើមឧស្សាហកម្មសម្រាប់ផលិតផលដូចជាជីកសិកម្ម ដែលអាចគាំទ្រការអភិវឌ្ឍទៅមុខនៃសេដ្ឋកិច្ចកម្ពុជា ក្នុងករណីសិក្សាឃើញថា តាមលក្ខណៈសេដ្ឋកិច្ច មិនទទួលផលចំណេញពីការពង្រាវឧស្ម័ន ឬការកសាងបំពង់នាំឧស្ម័នចេញទេនោះ[62]។

## ៥. ករណីសិក្សា

ប្រទេសម៉ិកស៊ិកូ និងទីម័រខាងកើត ត្រូវបានជ្រើសរើសសម្រាប់ករណីសិក្សា ពីព្រោះប្រទេសទាំងពីរនេះជាប្រទេសកំពុងអភិវឌ្ឍ[63] ហើយក្នុងលក្ខខណ្ឌទូទៅ ប្រទេសទាំងពីរនេះ មានសមត្ថភាពស្ថាប័នក្នុងកម្រិតអាចប្រៀបធៀបគ្នាបាន។ ដូច្នេះហើយ ដូចបានបញ្ជាក់ច្បាស់ក្នុងអត្ថបទស្រាវជ្រាវខាងលើ ការអភិវឌ្ឍស្ថាប័នដែលមានលក្ខណៈសមស្រប ជាកត្តាសំខាន់ដើម្បីសម្រេចបាននូវលទ្ធផលវិជ្ជមានពីចំណូលប្រេង និងឧស្ម័ន។ ហេតុនេះ វាមានគុណតម្លៃសម្រាប់ការប្រៀបធៀបតិចតួច ក្នុងការដាក់បញ្ចូលករណីសិក្សាអំពីប្រទេសអភិវឌ្ឍន៍ ដូចជាប្រទេសកាណាដា ន័រវេស ឬសហរដ្ឋអាមេរិកឡើយ ពីព្រោះស្ថាប័នរបស់ប្រទេសទាំងនោះ មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងចំណូលមហាសាលនេះ។

### ៥.១ ប្រទេសម៉ិកស៊ិកូ

ការមិនមានសមត្ថភាពសងបំណុលសាធារណៈរបស់ប្រទេសម៉ិកស៊ីកូក្នុងឆ្នាំ១៩៨២ ជាឧទាហរណ៍សំខាន់មួយបង្ហាញពីវិបត្តិសេដ្ឋកិច្ច បណ្តាលមកពីការធ្វើវិនិយោគលើសលប់ក្នុងវិស័យប្រេង។ ក្រោយវិបត្តិប្រេងក្នុងឆ្នាំ១៩៧៣ ដែលបានធ្វើតម្លៃប្រេងកើនឡើងយ៉ាងខ្លាំង ប្រទេសម៉ិកស៊ីកូបានរកឃើញរ៉ែប្រេងដ៏ធំមួយចំនួន។ ក្នុងអំឡុងពេលនោះ ប្រទេសម៉ិកស៊ិកូ ឆ្លៀតឱកាសប្រើប្រាស់ប្រាក់កម្ចីការប្រាក់ទាប យកមកធ្វើការវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងគម្រោងរុករកប្រេង។ នៅពេលជាមួយគ្នានេះ ដើម្បីប្រជាប្រិយភាពនយោបាយ ប្រទេសម៉ិកស៊ិកូ បានបង្កើនការឧបត្ថម្ភធនលើទំនិញសំខាន់ៗដូចជាស្បៀងអាហារជាដើម។

ការបង្កើនក្នុងការចំណាយនេះ បានធ្វើឲ្យកើនឡើននូវអត្រាអតិផរណាដល់កម្រិតគ្រោះថ្នាក់ និងបង្កឲ្យមានផលលំបាកក្នុងវិស័យសេដ្ឋកិច្ចផ្សេងទៀត។ ក៏ប៉ុន្តែ ការខូចខាតធ្ងន់ធ្ងរបំផុត បានកើតឡើងក្នុងឆ្នាំ១៩៨២ នៅពេលតម្លៃប្រេងយ៉ាងបានធ្លាក់ចុះយ៉ាងឆាប់រហ័ស និងអត្រាការប្រាក់អន្តរជាតិ

[62]World Bank, *Introduction to Oil and Gas*, Cambodia Oil & Gas Briefing Notes (Washington DC: World Bank, 2007), http://siteresources.worldbank.org/INTOGMC/Resources/cambodia_oil_gas_newsletter_15.pdf

[63]"Country and Lending Groups | Data," October 22, 2013, http://data.worldbank.org/about/country-and-lending-groups; IMF, *World Economic Outlook: April 2014* (Washington DC: IMF, 2014), http://www.imf.org/external/pubs/ft/weo/2014/01/pdf/text.pdf.

បានកើនឡើង មានន័យថារដ្ឋនៃប្រទេសម៉ិកស៊ិកូ មិនមានលទ្ធភាពសងបំណុលដ៏ច្រើនសន្ធឹកសន្ធាប់របស់ខ្លួនបានឡើយ[64]។ ប៉ុន្មានទសវត្សរ៍ក្រោយមក ប្រទេសម៉ិកស៊ិកូ នៅតែជាប់បំណុលសាធារណៈខ្ពស់ មានមូលដ្ឋានឧស្សាហកម្មទន់ខ្សោយ និងចំណូលរដ្ឋាភិបាលមិនមានស្ថេរភាព ដោយសារការពឹងផ្អែកខ្លាំងពេកលើចំណូលពីប្រេង និងការរំពឹងទុកជ្រុលពេកអំពីផលចំណេញ ពីប្រេង[65]។

មេរៀនដែលអាចយកមកអនុវត្តក្នុងប្រទេសកម្ពុជានោះ គឺសារៈសំខាន់នៃគោលនយោបាយសេដ្ឋកិច្ចមានប្រសិទ្ធភាពរយៈពេលវែង ដែលមានភាពចាំបាច់ក្នុងការធ្វើឲ្យមានស្ថេរភាពនូវចំណូលប្រេង និងឧស្ម័នដែលមិនមានភាពទៀតទាត់។

## ៥.២ ប្រទេសទីម័រខាងកើត

ក្នុងឆ្នាំ២០០២ បន្ទាប់ពីមានការកាន់កាប់ពីបរទេស និងអំពីហិង្សាជាងពីរទសវត្សរ៍ ប្រទេសទីម័រខាងកើត បានលេចចេញជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងពិភពលោក ដែលមានហេដ្ឋារចនាសម្ព័ន្ធ វិស័យអប់រំ និងសមត្ថភាពរដ្ឋមានកម្រិតទាបបំផុត[66]។ ដូចគ្នានឹងប្រទេសកម្ពុជាដែរ ប្រេងបម្រុងរបស់ប្រទេសទីម័រខាងកើត មានបរិមាណទាប ធៀបនឹងប្រទេសឯទៀតក្នុងពិភពលោក ប៉ុន្តែជាបរិមាណខ្ពស់ ធៀបនឹងទំហំសេដ្ឋកិច្ចជាតិ។ ប្រេងបម្រុងក្នុងប្រទេសទីម័រខាងកើត មានបញ្ហាចំបងចំនួនបី ៖ ទីមួយ តើត្រូវការពារធនធានប្រេងឲ្យរួចផុតពីអំពើពុករលួយដោយវិធីណា ទីពីរ តើត្រូវប្រើប្រាស់ធនធានប្រេង ដើម្បីជួយជំរុញការអភិវឌ្ឍដោយវិធីណា ដោយសារប្រទេសនេះមានសេដ្ឋកិច្ចតូច និងមានសមត្ថភាពស្ដួចស្ដើងដើម្បីស្រូបយកដើមទុន និងទីបី តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យមានតុល្យភាពរវាងការចំណាយបច្ចុប្បន្ន និងប្រាក់សន្សំ[67]។

បញ្ហាទីមួយ ត្រូវបានដោះស្រាយ តាមរយៈការបង្កើតមូលនិធិវិនិយោគរបស់រដ្ឋ (Sovereign Wealth Fund) ដោយយកគំរូតាមប្រទេសន័រវេស។ តាមច្បាប់ មូលនិធិនេះ ទទួលចំណូលទាំងអស់ពីប្រេង និងឧស្ម័ន ។ មូលនិធិនេះ ត្រូវបានចាត់ចែងដោយធនាគារកណ្ដាល ហើយការដកប្រាក់ អាចធ្វើឡើង ដើម្បីផ្ដល់ហិរញ្ញប្បទានដល់ថវិការដ្ឋដោយផ្ទាល់តែប៉ុណ្ណោះ នូវចំនួនទឹកប្រាក់ ដែលត្រូវបានកំណត់មិនឲ្យលើសបីភាគរយនៃទ្រព្យប៉ាន់ស្មានសរុបរបស់ប្រទេសទីម័រខាងកើត ដែលទទួលបាន

---

64 Tim Merrill and Miro Ramon, *Mexico: A Country Study* (Washington DC: Library of Congress, 1996), http://lcweb2.loc.gov/frd/cs/mxtoc.html. Ch. 'Recovery and Relapse, 1976-82'.

65 Nick Dearden, "Thirty Years since Mexico's Default, Greece Must Break This Sadistic Debt Spiral," *New Statesman*, 2012, Online edition, http://www.newstatesman.com/blogs/economics/2012/08/thirty-years-mexicos-default-greece-must-break-sadistic-debt-spiral.

66 "CIA World Factbook: Timor Leste," *CIA World Factbook*, 2014, https://www.cia.gov/library/publications/the-world-factbook/geos/tt.html.

67 HengDyna and Ngo Sothath, *Extractive Industries Revenue Management: A Tale of Six Countries* (Phnom Penh: Cambodia Economic Association, 2013). pp. 7-9.

ប្រេង និងឧស្ម័ន ដើម្បីជាប្រយោជន៍ក្នុងការរក្សាឲ្យបានមូលនិធិរយៈពេលវែង ដើម្បីបម្រើប្រជាជនជំនាន់ក្រោយ [68]។

បញ្ហាទីពីរ តើត្រូវប្រើចំណូលក្នុងប្រទេសមានសេដ្ឋកិច្ចតូច ដែលមានសមត្ថភាពស្តួចស្តើង ដើម្បីស្រូបយកដើមទុនដោយវិធីណា ដោយមិនបង្កឲ្យមានផលប៉ះពាល់អវិជ្ជមាននានា ដូចជា អតិផរណាខ្ពស់ជាដើម។ ប្រទេសទីម័រខាងកើត ដោយមានការគាំទ្រពីធនាគារពិភពលោក បានអនុវត្តវិធីសាស្ត្របង្កើនថវិកាជាបណ្តើរៗ (Gradual Scaling Approach) ដោយផ្តោតលើការប្រើប្រាស់ចំណូល ដើម្បីពង្រីកសេដ្ឋកិច្ចដែលមិនទាក់ទងនឹងប្រេង ក្នុងប្រទេសទីម័រខាងកើត តាមរយៈការវិនិយោគក្នុងវិស័យនានា ដូចជា កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងអប់រំ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ដោយបង្កើនការប្រើប្រាស់ពីចំណូលពីប្រេង និងឧស្ម័ន[69]។

បញ្ហាចំបងទីបីទាក់ទងនឹងចំណូលពីប្រេង និងឧស្ម័នរបស់ប្រទេសទីម័រខាងកើត ដែលអាចជាបញ្ហាចម្រូងចម្រាស់បំផុត ដោយសារបញ្ហានៃការធ្វើឲ្យមានតុល្យភាពរវាងការប្រើប្រាស់ចំណូលពីប្រេងក្នុងពេលបច្ចុប្បន្ន និងប្រាក់សន្សំ និងការចំណាយក្នុងពេលអនាគត ត្រូវការចម្លើយប៉ាន់ស្មានចំពោះចំណោទបញ្ហាស្មុគស្មាញចំនួនពីរ គឺ៖ តើបរិមាណប្រេងសរុប មានតម្លៃជាទឹកប្រាក់ចំនួនប៉ុន្មាន? និងថាតើមានផលប្រយោជន៍អ្វីខ្លះ ក្នុងការចំណាយ ឬការសន្សំចំណូលពីប្រេង?[70] មិនមានចម្លើយជាក់លាក់ចំពោះចំណោទបញ្ហាទាំងនេះទេ ពីព្រោះចម្លើយទាំងនេះ ជាប់ទាក់ទងនឹងស្ថានភាពជាច្រើនដែលយើងមិនដឹង។ ឧទាហរណ៍ ដើម្បីប៉ាន់ស្មានចំណូលពីប្រេង យើងត្រូវពិចារណាអំពីតម្លៃប្រេងក្នុងពេលអនាគត លទ្ធភាពបច្ចេកទេសនៃការរុករក និងដឹកជញ្ជូនប្រេង និងបញ្ហាប្រឈមនៃសន្តិសុខក្នុងតំបន់ក្នុងពេលអនាគត។ ដើម្បីកំណត់តុល្យភាពរវាងការចំណាយ និងការសន្សំ យើងត្រូវប៉ាន់ស្មានថាតើសេដ្ឋកិច្ច អាចស្រូបយកដើមទុនចំនួនប៉ុន្មាន និងថាតើកម្មវិធីអភិវឌ្ឍរយៈពេលខ្លីដ៏រឹងមាំ នឹងផ្តល់ប្រយោជន៍យ៉ាងដូចម្តេចខ្លះចំពោះអនាគតរបស់ប្រទេស ទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់ស្ថេរភាព វិស័យអប់រំ ហេដ្ឋារចនាសម្ព័ន្ធ និងស្ថានភាពការងារ ធៀបទៅនឹងការអភិវឌ្ឍមូលនិធិសន្សំរយៈពេលវែងសម្រាប់អនាគតរបស់ប្រទេស[71]។

វិធីសាស្ត្ររយៈពេលវែង ដែលទទួលបានជោគជ័យគួរឲ្យកត់សម្គាល់របស់ប្រទេសទីម័រខាងកើត អាចជាប្រធានបទនៃការសិក្សាស្រាវជ្រាវបន្ថែម ពីព្រោះមានស្ថានភាពស្រដៀងគ្នាមួយចំនួនរវាងប្រទេសទាំងពីរ ដែលជាប្រទេសមានសេដ្ឋកិច្ចតូច , មិនមានលទ្ធភាពស្រូបយកវិនិយោគទុនធំៗនៅឡើយ, មានពិន្ទុសន្ទស្សន៍នៃអភិវឌ្ឍប្រជាជនទាប ហើយភាពកាន់តែស្រដៀងគ្នានោះ គឺសមត្ថភាពស្ថាប័ននៅមានកម្រិត។

---

[68] ដូចជើងទំព័រខាងលើ ទំព័រ 7-8.

[69]World Bank and Independent Evaluation Group, *Timor-Leste Country Program Evaluation, 2000-2010*. pp. xvii-xviii

[70]Dyna and Sothath, *Extractive Industries Revenue Management: A Tale of Six Countries*. pp. 9; World Bank and Independent Evaluation Group, *Timor-Leste Country Program Evaluation, 2000-2010*.

[71]Michael, *The Oil Curse*. pp. 223-254.

## ៦. សេចក្តីសន្និដ្ឋាន

ដូចបានបង្ហាញក្នុងឯកសារស្រាវជ្រាវសង្ខេបនេះ ចំណូលពីប្រេង និងឧស្ម័ន មិនតែងតែផ្តល់ផលប្រយោជន៍ជាសំខាន់ដល់ប្រទេសមួយឡើយ បើសិនមិនមានការគ្រប់គ្រងឲ្យបានសមស្របសម្រាប់រយៈវែងទេនោះ។ ការគ្រប់គ្រងនេះ ចាប់ផ្តើម នៅពេលមានលក្ខខណ្ឌកិច្ចសន្យាត្រឹមត្រូវ ដើម្បីធ្វើឲ្យមានតុល្យភាព រវាងតម្រូវការទាក់ទាញវិនិយោគទុនសម្រាប់គម្រោងរុករកធំៗ ដែលមានហានិភ័យ និងតម្រូវការរបស់រដ្ឋក្នុងការទទួលបានសួយសារសមស្រប។ ចំណែកឯការគ្រប់គ្រងចំណូលក៏មានភាពស្មុគស្មាញផងដែរ។ ក៏ប៉ុន្តែ មានទម្រង់នៃការគ្រប់គ្រងដែលមានស្រាប់មួយចំនួន ដែលបានអនុវត្តក្នុងប្រទេសមួយចំនួន និងត្រូវបានសិក្សាយ៉ាងទូលំទូលាយ។ វិធីសាស្ត្រដែលសមស្របបំផុត ផ្អែកលើកត្តាមួយចំនួន ដូចជាកម្រិតនៃការអភិវឌ្ឍ និងសមត្ថភាពស្ថាប័ន។ ទោះជាយ៉ាងនេះក្តី វិធីសាស្ត្របង្កើនថវិកាជាបណ្តើរៗ (Gradual Scaling Approach) ដែលធ្វើឲ្យមានតុល្យភាពរវាងប្រាក់សន្សំរយៈពេលវែង និងស្ថេរភាព ទៅនឹងតម្រូវការកាត់បន្ថយភាពក្រីក្រ តាមរយៈការវិនិយោគសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច កំពុងអនុវត្តបានល្អក្នុងប្រទេសទីម័រខាងកើត និងអាចមានភាពទាក់ទងជាមួយនឹងប្រទេសកម្ពុជា ក៏ប៉ុន្តែនៅមានហានិយភ័យមួយចំនួនពាក់ព័ន្ធនឹងចំណូលប្រេង និងឧស្ម័ន ដូចជាអស្ថេរភាពសេដ្ឋកិច្ចដ៏ធំ ឬអំពើពុករលួយ។ ទោះបីយ៉ាងនេះក្តី មានគោលនយោបាយដែលបានសិក្សាយ៉ាងត្រឹមត្រូវមួយចំនួន ដើម្បីបញ្ចៀសហានិយភ័យនេះ និងបង្កើនផលចំណេញឲ្យដល់កម្រិតអតិបរមា។ គោលនយោបាយជាគន្លឹះ គឺការអភិវឌ្ឍស្ថាប័នឲ្យបានសមស្របដើម្បីគ្រប់គ្រងធនធានប្រេង និងឧស្ម័ន។

# គន្ថនិទ្ទេស


Arezki, Rabah, and Markus Brückner. *Oil Rents, Corruption, and State Stability: Evidence from Panel Data Regressions*. IMF Working Paper. Washington DC: IMF, 2009. http://www.sciencedirect.com/science/article/pii/S0014292111000316.

Barnett, Steven, and Rolando Ossowski. “Operational Aspects of Fiscal Policy in Oil-Producing Countries.” IMF, 2002.

Berg, Andrew, Rafael Portillo, Shu-Chun S. Yang, and Luis-Felipe Zanna. “Public Investment in Resource-Abundant Developing Countries.” *IMF Economic Review* 61, no. 1 (2013): 92–129.

“Chevron To Sell Shares of Cambodian Offshore Oil and Gas.” *VOA*. Accessed August 15, 2014. http://www.voacambodia.com/content/chevron-to-sell-shares-of-cambodian-offshore-oil-and-gas/2413411.html.

“CIA World Factbook: Timor Leste.” *CIA World Factbook*, 2014. https://www.cia.gov/library/publications/the-world-factbook/geos/tt.html.

Clark, Helen. “Avoiding the Resource Curse: Managing Extractive Industries for Human Development.” In *Keynote Speech*. Ulaanbaatar: UNDP, 2011. http://www.undp.org/content/undp/en/home/presscenter/speeches/2011/10/20/helen-clark-avoiding-the-resource-curse-managing-extractive-industries-for-human-development-/.

Collier, Paul. “The Political Economy of Natural Resources: Interdependence and Its Implications,” 2009. https://depot.gdnet.org/newkb/submissions/paul%20collier_paper_p2.pdf.

“Country and Lending Groups | Data,” October 22, 2013. http://data.worldbank.org/about/country-and-lending-groups.

Darby, Michael R. “The Permanent Income Theory of Consumption--A Restatement.” *The Quarterly Journal of Economics* 88, no. 2 (May 1974): 228. doi:10.2307/1883070.

Deacon, Robert, T, and Bernardo Mueler. “Political Economy and Natural Resouce Use.” In *Economic Development and Environmental Sustainability*, edited by Ramon Lopez and Michael Toman A. Oxford: Oxford University Press, 2006.

Dearden, Nick. “Thirty Years since Mexico’s Default, Greece Must Break This Sadistic Debt Spiral.” *New Statesman*, 2012, Online edition. http://www.newstatesman.com/blogs/economics/2012/08/thirty-years-mexicos-default-greece-must-break-sadistic-debt-spiral.

Dyna, Heng, and Ngo Sothath. *Extractive Industries Revenue Management: A Tale of Six Countries*. Phnom Penh: Cambodia Economic Association, 2013.

EITI. *EITI Fact Sheet*. Oslo: EITI. Accessed July 28, 2014. http://eiti.org/document/factsheet.

———. *EITI Rules*. Oslo: EITI. Accessed July 28, 2014. http://eiti.org/document/rules.

Frankel, Jeffrey, A. *The Natural Resources Curse: A Survey of Diagnoses and Some Prescriptions*. Working Paper. Faculty Research Working Paper Series. Cambridge, MA: Harvard University, Kennedy School of Government, 2012.

Ghura, Dhaneshwar, and Catherine Pattillo. “Too Much of a Good Thing?” *Finance & Development* 50, no. 3 (2013): 9.

Iacono, Roberto. “Is It Really Worse with a Bird in  Hand? A Comparison of Fiscal Rules  for Resource-Rich Economies.” Norwegian University of Science and Technology, 2012.

“IISS.” Accessed July 28, 2014. http://www.iiss.org/en/iiss%20voices/blogsections/iiss-voices-2013-1e35/march-2013-6eb6/avoiding-resource-curse-65e7.

IMF. *Cambodia: Selected Issues and Statistical Appendix*. Country Report. Washington DC: IMF, 2007. http://www.imf.org/external/pubs/ft/scr/2007/cr07291.pdf.

———. *Macroeconomic Policy Frameworks for Resource-Rich Developing Countries*. Paris: IMF, 2012.

———. *World Economic Outlook: April 2014*. Washington DC: IMF, 2014.
http://www.imf.org/external/pubs/ft/weo/2014/01/pdf/text.pdf.

Kent, Sarah. “Nigeria Loses Billions to Inefficiencies in Oil Sector - Watchdog.” *Wall Street Journal*, July 30, 2013, sec. Markets. http://online.wsj.com/news/articles/SB10001424127887324809004578637443141740504.

Merrill, Tim, and Miro Ramon. *Mexico: A Country Study*. Washington DC: Library of Congress, 1996. http://lcweb2.loc.gov/frd/cs/mxtoc.html.

Michael, Ross. *The Oil Curse*. Princeton: Princeton University Press, 2012.
"Oil and Gas Blocks | Open Development Cambodia." Accessed August 18, 2014. http://www.opendevelopmentcambodia.net/briefing/oil-and-gas-blocks/.
Richmond, Christine J., Irene Yackovlev, and Ms Shu-Chun S. Yang. *Investing Volatile Oil Revenues in Capital-Scarce Economies: An Application to Angola*. 13-147. International Monetary Fund, 2013. http://books.google.com/books?hl=en&lr=&id=AL1ZLw8zPYwC&oi=fnd&pg=PP1&dq=%22The+Government%22+%22Parameter+Calibration%22+%22and+third+largest+economy.+The+civil+war,+which+ended+in+2002,%22+%22gaps+underscores+the+challenges+faced+by+capital-scarce+developing%22+%22prices+stayed+up,+leading+to+the+belief+that+they+were+permanent,+spending%22+&ots=bXVIFq3GYp&sig=BMgAkQXM5orrAaZM6U-tyhOzPq8.
Sachs, Jeffrey. "How to Handle the Macroeconomics of Oil Wealth." In *Escaping the Resource Curse*, edited by Macartan Humphreys, Jeffrey Sachs, and Joesph E. Stiglitz. New York: Columbia University Press, n.d.
Sachs, Jeffrey, and Andrew Warner. *Natural Resource Abundance and Economic Growth*. Working Paper. Cambridge, MA: National Bureau of Economic Research, 1995. http://www.nber.org/papers/w5398.pdf.
Segura, Alonso. *Management of Oil Wealth under the Permanent Income Hypothesis: The Case of São Tomé and Príncipe*. Vol. 6. International Monetary Fund, 2006. http://books.google.com/books?hl=en&lr=&id=GesTSNZ0cVgC&oi=fnd&pg=PA4&dq=%222004+may+offer+the+best+chance+for+the+country+to+put+in+place+strong%22+%22sustainable+government+consumption+and+intergenerational+equity+while%22+%22of+US%243+billion.+These+figures+are+noticeably+high,+considering+that+for+2006+the%22+&ots=qhr_mh_XHl&sig=WT__K5XdcTEP6C76qKFDqKCy3Fg.
"Shell's Massive Prelude Hull World's Biggest-Ever Floating Vessel and First Ocean-Based LNG Plant." *Financial Post*. Accessed August 15, 2014. http://business.financialpost.com/2013/12/03/record-breaking-lng-ship-launched-bigger-one-planned/.
Stevens, Paul, and Matthew Hulbert. *Oil Prices: Energy Investment, Political Stability in the Exporting Countries and OPEC's Dilemma*. Chatham House, 2012. http://www.chathamhouse.org/sites/default/files/public/Research/Energy,%20Environment%20and%20Development/1012pp_opec.pdf.
The Economist. "The Curse of Oil: The Paradox of Plenty." *The Economist*. December 20, 2005, 20/12/2005 edition. http://www.economist.com/node/5323394.
UNDP. *Review of Development Prospects and Options For the Cambodian Oil and Gas Sector*. Discussion Paper. Insights for Action. Phnom Penh: UNDP Cambodia, 2006.
World Bank. *Contracts for Petroleum Development - Part 1*. Cambodia Oil & Gas Briefing Notes. Washington DC: World Bank, 2007. http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTOGMC/0,,contentMDK:21852379~menuPK:5242468~pagePK:210058~piPK:210062~theSitePK:336930,00.html#CambodiaO&GNotes.
———. *Contracts for Petroleum Development - Part 2*. Cambodia Oil & Gas Briefing Notes. Washington DC: World Bank, 2007. http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTOGMC/0,,contentMDK:21852379~menuPK:5242468~pagePK:210058~piPK:210062~theSitePK:336930,00.html#CambodiaO&GNotes.
———. *Contracts for Petroleum Development - Part 3*. Cambodia Oil & Gas Briefing Notes. Washington DC: World Bank, 2008. http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTOGMC/0,,contentMDK:21852379~menuPK:5242468~pagePK:210058~piPK:210062~theSitePK:336930,00.html#CambodiaO&GNotes.
———. *Extractive Industries Transparency Initiative*. Cambodia Oil & Gas Briefing Notes. Washington DC: World Bank, 2007. http://siteresources.worldbank.org/INTOGMC/Resources/cambodia_oil_gas_newsletter_15.pdf.

———. *Introduction to Oil and Gas*. Cambodia Oil & Gas Briefing Notes. Washington DC: World Bank, 2007. http://siteresources.worldbank.org/INTOGMC/Resources/cambodia_oil_gas_newsletter_15.pdf.

———. *Oil and Gas: A Blessing or a Curse?* Cambodia Oil & Gas Briefing Notes. Washington DC: World Bank, 2007. http://siteresources.worldbank.org/INTOGMC/Resources/cambodia_oil_gas_newsletter_2.pdf.

World Bank, and Independent Evaluation Group. *Timor-Leste Country Program Evaluation, 2000-2010: Evaluation of the World Bank Group Program*. Washington, D.C.: World Bank Group, Independent Evaluation Group, 2011.

Zakharova, Daria, and Ms Charleen Gust. *Strengthening Russia's Fiscal Framework*. 12-76. International Monetary Fund, 2012. http://books.google.com/books?hl=en&lr=&id=DdlViXWhiHEC&oi=fnd&pg=PP2&dq=%22Hard+Landing,+Forceful+Response,+and+Difficult+Road+Ahead%22+%22Traditional+and+Nonoil+Fiscal+Indicators,+2004%E2%80%9310%22+%22the+rate+of+extraction+of+oil,+and+the+use+of+oil+revenue+have+significant%22+&ots=_CqBZ0TRPo&sig=rIw9vWoW3w_S4bysNVz14AeaoLg.

Zhang, Yanchun, and Office of Development Studies, UNDP. "Managing Resource Revenue in the Context of Increasing Commodity Price Volatility." Ulaanbaatar: UNDP, 2011. http://www.undp.mn/mining/index.php?page=6.